# វិន័យសង្ខេប

ថ្នាក់បច្ឆិមភូមិ

## ផ្នែកសង្ឃកម្ម

សម្រាប់សិស្សធម្មវិន័យថ្នាក់ឯក

និង

សិស្សថ្នាក់ឆ្នាំទី ៤ នៃពុទ្ធិកវិទ្យាល័យ

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៣៩

## ផ្សាយចេញពី

# www.haotrai.com

## ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# វិន័យសង្ខេប

## ថ្នាក់បច្ឆិមភូមិ

# ផ្នែកសង្ឃកម្ម

សម្រាប់សិស្សធម្មវិន័យថ្នាក់ឯក

និង

សិស្សថ្នាក់ឆ្នាំទី ៤ នៃពុទ្ធិកវិទ្យាល័យ

បោះពុម្ពឡើងវិញ ចំនួន ១៥០០ ច្បាប់

តាមច្បាប់បោះពុម្ព ឆ្នាំ ១៩៦៥

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៣៩ គ.ស ១៩៩៥

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " វិន័យសង្ខេប ផ្នែកសង្ឃកម្ម " នេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូតូស៊ូជប៉ុន ( Japan Sotoshu Relief Committee " JSRC " ) និងពីមូលនិធិនៃអង្គការ រិស្សូ កូសី-កៃ (Rissho Kosei-Kai " RKK" ) ។

គោលបំណងនៃការបោះពុម្ពឡើងវិញ គឺសំដៅ :

- ផ្តល់ប្រគេនព្រះសង្ឃ ពិសេស សមណសិស្សដែលរៀនភាសាបាលី និងធម្មវិន័យ មានក្បួនច្បាប់សម្រាប់សិក្សារៀនសូត្រ និងយល់ដឹងបានត្រឹមត្រូវវិធីសង្ឃកម្ម ។
- រក្សាមរតកវប្បធម៌ អក្សរសាស្ត្រសាសនាអោយគង់វង្សនិងរីកចំរើន ។

ការបោះពុម្ពឡើងវិញនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ដោយហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុនចំពោះកង្វះខាតផ្សេងៗដែលអាចកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសូតូស៊ូជប៉ុន និងអង្គការរិស្សូ កូសី-កៃ ដែលបានជួយឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែឧសភា ឆ្នាំ ១៩៩៥

ពុទ្ធសាសនបណ្ឌិត្យ

## ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ដោយមានការឧបត្ថម្ភខាងថវិកាពី

អង្គការ រិស្សូ កូសី-កៃ

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជា-ជនកម្ពុជា ។

## Acknowledgement

This book has been printed by Japan Sotoshu Relief Committee (JSRC) with the financial support from

**Rissho Kosei-Kai** (RKK)

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.

# វិន័យសង្ខេប

ថ្នាក់បច្ចិមភូមិ

ផ្នែកសង្ឃកម្ម

ការរៀបរៀង

របស់

មហា-សោម-សុវណ្ណ (វិនយធរោ)

ពិនិត្យកែ

សម្តេចព្រះសង្ឃរាជថ្នាក់ទី ១

ជោតញ្ញាណោ (ជ-ណ)

វត្តឧណ្ណាលោម ក្រុងភ្នំពេញ,

បោះពុម្ពលើកទី ១ ចំនួន ១.០០០ក្បាល

រក្សាសិទ្ធិ

# អាទិកថា

ចុព្វហេតុដែលនាំឲ្យកើតសៀវភៅ "វិន័យសង្ខេប„ នេះឡើងដោយមានសិស្សពុទ្ធិកវិទ្យាល័យថ្នាក់ឆ្នាំទី ៤ ដែលបំរុងនឹងប្រឡងចេញព្រមទាំងពួកសិស្សដែលត្រូវសិក្សាធម្មវិន័យថ្នាក់ឯក, បានមកនិយាយស្នើនឹងខ្ញុំឲ្យរៀបរៀងព្រះវិន័យសំរាប់សិក្សាធម្មវិន័យថ្នាក់ឯក, ព្រោះផ្នែកខាងព្រះវិន័យពិតមែនតែអ្នកប្រាជ្ញ លោករៀបរៀងក្បួនច្បាប់មានច្រើនហើយក៏ដោយ ប៉ុន្តែនៅខ្វះត្រង់វិន័យ ផ្នែកខាងសង្ឃកម្មពុំទាន់មានបរិបូណ៌នៅឡើយ ។

អាស្រ័យហេតុនេះ ទើបខ្ញុំក៏ឆ្លៀតយកឧកាសដើម្បីរៀបរៀងនូវព្រះវិន័យនេះ តែការរៀបរៀងនេះ ខ្ញុំបានដកស្រង់តាមគោលរបស់ព្រះតេជ-គុណព្រះមហា ស៊ុន – ស៊ាន ជាបិយាចារ្យរបស់ខ្ញុំដែលជាបែបប្រកបឡើងមួយចំណែក តាំងពីកណ្ឌទី ២៣ ហូតដល់កណ្ឌទី ៣៣ រួចខ្ញុំបានយកវិន័យបិដកពួកខន្ធកៈខ្លះៗ មានកឋិនក្ខន្ធកជាដើមមកពិនិត្យសេចក្តីថែមទៀត ។ ខ្ញុំបានរៀបរៀងជាគោលខ្លី ១ ដើម្បីឲ្យស្រួលដល់ការទន្ទេញឲ្យចាំមាត់ ហើយនៅខាងចុងមានភាគកម្មវាចាផ្សេងៗ មានកម្មវាចាសីមាជាអាទិ ប៉ុន្តែភាគកម្មវាចាមិនបានគ្រប់គ្រាន់ទេ សូមសិក្ខាកាមកុលបុត្រទាំងឡាយគប្បីត្រួតមើលក្នុងទីដទៃទៀតផងចុះ ។

„វិន័យសង្ខេប„ នេះខ្ញុំយល់ឃើញថាជាហិតប្រយោជន៍ដល់ផ្នែកបព្-

ដិតក្នុងសាសនមណ្ឌលទូទៅ ព្រោះព្រះវិន័យជាឫសគល់ឬជាអាយុជីវិតនៃព្រះពុទ្ធសាសនា ។ ខ្ញុំរៀបរៀងចប់ហើយដោយមានអ្នកពិនិត្យផ្ទៀងផ្ទាត់គឺ ៖

១— ព្រះតេជ-គុណ(សួរ-ដិត) ព្រះបាឡាត់គណ(ជាចៅអធិការ) វត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង,

២— សម្តេចព្រះវ័នរ័ត(អ៊ុំ-ទូត) រាជាគណៈថ្នាក់ឯក មេគណខេត្តបាត់ដំបង,

៣— សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ បានជួយពិនិត្យដោយអន្ទើៗ ដោយព្រះអង្គមានព្រះរោគាពាធពុំសូវមានសុខភាព ។

បុញ្ញរាសី ដែលខ្ញុំបានហើយ ដោយឧស្សាហភាពក្នុងការរៀបរៀងវិន័យសង្ខេបនេះ ខ្ញុំមានបីតិនិងប្រាមោទ្យជាយ៉ាងក្រៃលែង ចំពោះករណី-យ៍នេះ សូមលើកឡើងជាព្រះរាជកុសលថ្វាយចំពោះ ៖

— សម្តេចព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ,

ព្រះសង្ឃគ្រប់អង្គក្នុងសាសនមណ្ឌល -

សូមព្រះអង្គប្រកបដោយសិរីសុវត្ថិវឌ្ឍនសុភមង្គល វិបុលសុខ តេជះជោគជ័យ ទីឃាយុ ជានិច្ចនិរន្តរ៍ តរៀងទៅ ។

ម្យ៉ាងទៀត ខ្ញុំសូមឧទ្ទិសកុសលនេះ ប្រគេន – ជូនចំពោះមាតាបិតា គ្រូឧបជ្ឈាយាចារ្យនិងបុព្វការីជនទាំងឡាយរបស់ខ្ញុំសូមអនុមោទនាទទួលយកនូវឧស្សន្នកសលនេះ ហើយសូមឲ្យបានសំរេចឥដ្ឋមនុញ្ញផលតាមសមគួរដល់សេចក្ដីប្រាថ្នា ។

ចំណែកខ្លួនខ្ញុំ ក៏សូមឲ្យបានជួបប្រទះតែនឹងសុខវឌ្ឍន៍ និទុក្ខ និភ័យ ឧបទ្រពចង្រៃទាំងក្នុងឥធលោកទាំងក្នុងបរលោក ។

ចិរំ តិដ្ឋតុ វិនយោ ! សកលលោកេ ផរតុ ពុទ្ធសាសនំ ! សូមឲ្យព្រះវិន័យស្ថិតស្ថេរចិរកាល ! សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅក្នុងសាកលលោក ។

ជាពិសេស:

សូមសិក្ខាកាមអ្នកសិក្សា សំរេចវិទ្យាបានគ្រប់យ៉ាង<br>
ច្បាប់លោកច្បាប់ធម៌ទាំងសងខាង, ប្រើបានសព្វយ៉ាងក្នុងស្រុកខ្មែរ

មហា សោម-សុវណ្ណ (វិនយធរោ)<br>
វត្តឧត្តមសម្បត្តិហាក៌ (រំដួល)<br>
ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង<br>
ថ្ងៃទី ៤ ខែឧសភា ឆ្នាំ<br>
ព.ស. ២៥០៧

គ.ស.១៩៦៤

# រតនបណាម

ពុទ្ធោ តិលោកទីបោវ ពុទ្ធោ សុរិយោ តមោនុទោ
យេ សន្តិ សរណំ ពុទ្ធំ នត្ថិ តេសំ ទុក្ខំ សទា ។

*ព្រះពុទ្ធជាពន្ទឺនៃសត្វក្នុងត្រៃលោក ព្រះពុទ្ធអាចបន្ទោបង់នូវងងឹត គឺមោហៈ បីដូចជាព្រះអាទិត្យ, បើអ្នកទាំងឡាយណាបានដល់ព្រះពុទ្ធជាទីពឹង ទុក្ខគ្មានដល់អ្នកទាំងឡាយនោះសព្វ ៗ កាល ៗ*

ធម្មោ តិលោកទីបោវ ធម្មោ សុរិយោ តមោនុទោ
យេ សន្តិ សរណំ ធម្មំ នត្ថិ តេសំ ភយំ សទា ។

*ព្រះធម៌ជាពន្ទឺនៃសត្វក្នុងត្រៃលោក ព្រះធម៌អាចបន្ទោបង់នូវងងឹត គឺមោហៈ បីដូចជាព្រះអាទិត្យ បើអ្នកទាំងឡាយណាបានដល់នូវធម៌ជាទីពឹង ភ័យគ្មានដល់អ្នកទាំងឡាយនោះសព្វ ៗ កាល ៗ*

សង្ឃោ តិលោកទីបោវ សង្ឃោ សុរិយោ តមោនុទោ
យេ សន្តិ សរណំ សង្ឃំ អត្ថិ តេសំ សុខំ សទា ។

*ព្រះសង្ឃជាប្រទីបបំភ្លឺសត្វក្នុងត្រៃលោក ព្រះសង្ឃអាចកំចាត់បង់នូវងងឹតគឺមោហៈ បីដូចជាព្រអាទិត្យ, បើអ្នកទាំងឡាយណាបានដល់នូវព្រះសង្ឃជាទីពឹងសេចក្តីសុខមានដល់អ្នកទាំងឡាយនោះសព្វៗកាល ៗ*

# វិន័យសង្ខេប

## ថ្នាក់បច្ឆិមភូមិ

## កណ្ឌទី ២៣

## សង្ឃកម្ម

### សង្ឃកម្មមាន ៤ យ៉ាងគឺ=

១– អបលោកនកម្ម

២– ញត្តិកម្ម

៣– ញត្តិទុតិយកម្ម

៤– ញត្តិចតុត្ថកម្ម ។

កម្មដែលគ្រាន់តែប្រាប់គ្នាក្នុងទីប្រជុំសង្ឃ គឺមិនបាច់តាំងញត្តិ, មិនបាច់សូត្រអនុស្សាវនា, គឺគ្រាន់តែប្រកាសសេចក្តីព្រមព្រៀងរបស់សង្ឃ ហៅថា អបលោកនកម្ម ។

### អបលោកនកម្មមាន ៥ យ៉ាងគឺ =

១– និស្សារណា ការធ្វើនាសនៈសាមណេរ ដែលប្រទូសរ៉ាយព្រះពុទ្ធ ដូចក្នុងសិក្ខាបទទី១០នៃសប្បាណកវគ្គ បាចិត្តិយកណ្ឌ ។

២– ឱសារណា ការទទួលសាមណេរដែលប្រព្រឹត្តដូច្នោះហើយ ត្រឡប់ប្រព្រឹត្តល្អវិញ ឲ្យចូលមកកាន់គណៈវិញ ។

៣– កណ្ឌុកម្ម ការប្រកាសសុំអនុញ្ញាតកោរសក់ ឲ្យកុលបុត្រដែលទើបចូលមកបួស ដែលភិក្ខុត្រូវធ្វើដោយខ្លួនឯង ។

៤– ព្រហ្មទណ្ឌ ការប្រកាសដាក់ព្រហ្មទណ្ឌ គឺហាមមិនឲ្យភិក្ខុនិយាយដាស់តឿនដល់ភិក្ខុដែលប្រដៅក្រ ។

៥– កម្មលក្ខណៈ ការអបលោកន៍ចែកអាហារក្នុងពេលឆាន់ ។

កម្មដែលសង្ឃធ្វើដោយត្រឹមតែញត្តិមួយ ដោយអនុម័តិរបស់សង្ឃដែលព្រមព្រៀងគ្នាធ្វើ ហៅថា ញត្តិកម្ម ។

## ញត្តិកម្មមាន ៩ យ៉ាងគឺ=

១– ឱសារណា ការហៅឧបសម្បទាបេក្ខ ដែលបានសួរអន្តរា-យិកធម៌ហើយ ឲ្យចូលមកក្នុងជុំនុំសង្ឃ ។

២– និស្សារណា ការដកធម្មកថិកដែលមិនឈ្លាសក្នុងធម៌ចេញអំពីការរម្ងាប់អធិករណ៍ ។

៣– ឧបោសថ

៤ បវារណា

៥– សម្មតិ  សន្មតខ្លួនជាអ្នកសួរអន្តរាយិកធម៌

៦– ទានំ  ការឲ្យវិញនូវបាត្រ  ចីវរដែលត្រូវនិស្សគ្គិយជាដើម

៧– បដិគ្គហោ  ការទទួលអាបត្តិដែលភិក្ខុសំដែងក្នុងសង្ឃ ។

៨- បច្ចុក្កឌ្ឍនំ ប្រកាសពន្យារបវារណាចេញទៅមុខទៀត

៩ កម្មលក្ខណំ  បានដល់ប្រកាសផ្ដើមពិធីរម្ងាប់អធិករណ៍ដោយតិណវត្ថារកវិន័យ ។

កម្មដែលសង្ឃធ្វើដោយញត្តិមួយ  និងអនុស្សាវនាមួយដោយអនុម័តរបស់សង្ឃ ដែលព្រមព្រៀងគ្នា ហៅថា  ញត្តិទុតិយកម្ម ។

## ញត្តិទុតិយកម្មមាន ៧ យ៉ាងគឺ =

១– និស្សារណា  ផ្កាប់បាត្រប្រណាមគ្រហស្ថដែលប្រទូសរ៉ាយព្រះពុទ្ធសាសនា ។

២– ឧសារណា  ផ្ងារបាត្រដកប្រណាមគ្រហស្ថដូរបោះចេញ  ដែលត្រឡប់ប្រព្រឹត្តល្អវិញហើយ ។

៣- សម្មតិ  សន្មតរឿងខ្លះ  មានសន្មតសីមា  និងចៅនាទីដែលធ្វើការសង្ឃជាដើម ។

៤– ទានំ ការឲ្យផ្សេងៗ  មានឲ្យសំពត់កឋិនជាដើម ។

៥– ឧព្ភារោ ការប្រកាសដកឬបញ្ចប់អានិសង្សកឋិន ។

៦– ទេសនំ ការសំដែងទីកសាងកុដិ ។

៧– កម្មលក្ខណំ បានដល់ញត្តិទុតិយកម្ម ដែលសូត្រក្នុងលំដាប់នៃការរម្ងាប់អធិករណ៍ គឺដោយតិណវត្ថារកវិន័យ ។

កម្មដែលសង្ឃធ្វើដោយញត្តិមួយនិងអនុស្សាវនាបី ដោយអនុម័តរបស់សង្ឃ ដែលព្រមព្រៀងគ្នា ហៅថា ញត្តិចតុត្ថកម្ម ។

## ញត្តិចតុត្ថកម្មមាន ៧ យ៉ាងគឺ=

១– និស្សារណា បានដល់សង្ឃធ្វើកម្ម ៧ យ៉ាងមានតជ្ជនីយកម្មជាដើម ដល់ភិក្ខុដែលប្រព្រឹត្តខុស ។

២– ឧសារណា បានដល់សង្ឃលើកទោស ឲ្យដល់ភិក្ខុដែលត្រឡប់ប្រព្រឹត្តខ្លួនល្អវិញ ។

៣– សម្មតិ សន្មតឲ្យភិក្ខុឲ្យឱវាទដល់ភិក្ខុនី ។

៤– ទានំ ឲ្យបរិវាសនិងមានត្ត ។

៥– និគ្គហោ ដាក់ទោសភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត ហើយត្រូវអាបត្តិដូចឈ្មោះទៀត ឲ្យត្រឡប់ប្រព្រឹត្តសារដើមជាថ្មីវិញ ។

៦ សមនុភាសនំ សូត្រប្រកាសហាមឃាត់ មិនឲ្យភិក្ខុប្រកាន់

មាំនៅក្នុងការប្រកាន់ខុសនោះ ។

៧– កម្មលក្ខណ ការឲ្យឧបសម្បទនិងអព្ភានដល់អព្ភានារហភិក្ខុ ។

## កំណត់សង្ឃធ្វើកម្មមាន ៥ ប្រភេទគឺ =

១– ចតុវគ្គ សង្ឃមានចំនួន ៤រូប

២– បញ្ចវគ្គ សង្ឃមានចំនួន ៥រូប

៣ – ទសវគ្គ សង្ឃមានចំនួន ១០រូប

៤ - វីសតិវគ្គ សង្ឃមានចំនួន ២០រូប

៥ អតិរេកវីសតិវគ្គ សង្ឃមានចំនួនច្រើនលើសពី២០រូប ។

## កម្មវិបត្តិមាន ៤ យ៉ាងគឺ =

១ វត្ថុវិបត្តិ វិបត្តិដោយវត្ថុដូចជាបំបួសកុលបុត្រដែលមាន អាយុមិនគ្រប់២០ឆ្នាំជាដើម ។

២– សីមាវិបត្តិ វិបត្តិដោយសីមាគឺសីមាគាបសង្កត់សីមាជាដើម ។

៣ - បរិសាវិបត្តិ វិបត្តិដោយបរិស័ទគឺប្រជុំសង្ឃមិនគ្រប់អង្គតាមកំណត់ ។

៤ កម្មវាចាវិបត្តិ វិបត្តិដោយកម្មវាចាគឺសូត្រភ្លាំងភ្លាត់ឬខ្វះខាត

មិនត្រូវតាមរបៀបអក្ខរៈ គួរតាំងញត្តិឬសូត្រអនុសាវនាតែមិនតាំងញត្តិ មិនសូត្រអនុសាវនា ដូច្នេះជាដើមនេះ ហៅថា កម្មវិបត្តិ ។

## អក្ខរវិធី

អក្ខរៈ សំរាប់ប្រើក្នុងភាសាបាលីមាន ៤១ តួ គឺស្រៈ ៨ តួ ព្យញ្ជនៈ ៣៣ តួ ។ ស្រៈ ៨ តួនោះគឺ អ អា ឥ ឦ ឧ ឩ ឯ ឱ ។ ព្យញ្ជនៈ ៣៣ តួ នោះគឺៈ កខគឃង ចឆជឈញ ដឋឌឍណ តថទធន បផពភម ២៥ នេះហៅថាវគ្គ, យរលវសហឡ ំ ៨ តួនេះហៅថាអវគ្គ ឬសេសវគ្គ ។

អក្ខរៈ ទាំង ៤១ តួនេះមាន ឋាន ទីតាំងនៃកំណើតសំឡេង, ករណៈ លំនាំនៃការធ្វើសំឡេង, ឃោសៈ សំឡេងគឹកកង, អឃោសៈ មិនគឹកកង ។

## ឋាន, ទីកើតមាន ៦ យ៉ាងគឺ=

១– កណ្ឋជ កើតត្រង់កមាន ៨ តួគឺៈ អអាកខគឃងហ ។

២– តាលុជៈ កើតត្រង់ពិតានគឺក្រអូមមាត់មាន ៨ តួគឺៈ ឥឦចឆជឈញយ ។

៣– មុទ្ធជៈ កើតត្រង់ក្បាលមាន ៧ តួគឺៈ ដឋឌឍណរឡ ។

៤– ទន្តជៈ កើតត្រង់ប្រទល់ធ្មេញមាន ៨ តួគឺៈ តថទធនលស ។

៥– ឱដ្ឋជៈ កើតត្រង់បបូរមាត់មាន ៧ តួគឺ ឧ ឩ ប ផ ព ភ ម ។

៦– នាសិកជ កើតត្រង់ច្រមុះហៅថានិគ្គហិតគឺៈ ំ អក្ខរៈដែលមានសំឡេងកើតត្រង់កន្លែងតែមួយៗ ហៅថា ឯកដ្ឋានជៈ ។

## ឋានពិសេស

ឯនិងឱ ជាសំយុត្តសរៈ ឈ្មោះថាទ្វិដ្ឋានគឺស្រៈធំ ឯជាកណ្ឋតាលុជៈមានសំឡេងកើតត្រង់កនិងពិតាន ដ្បិតឯកើតពី អនិងឥ, ឱ ជាកណ្ឋោដ្ឋជៈមានសំឡេងកើតត្រង់កនិងប្រទល់បបូរមាត់ ត្បិតឱកើតពី អនិងឧ ។ ងញណនម ទាំង ៥ តួនេះហៅថាវគ្គន្ត ព្យញ្ជនៈបំផុតវគ្គ ជាសកដ្ឋាននាសិកជៈ មានសំឡេងកើតក្នុងឋានរបស់ខ្លួនៗនិងច្រមុះ ។ វជាទន្តោដ្ឋជៈ មានសំឡេងកើតក្នុងប្រទល់ធ្មេញ និងបបូរមាត់ ។ ហ តាមឋានដើមរបស់ខ្លួនជា កណ្ឋជៈ ប៉ុន្តែបើផ្សំជាមួយនឹងព្យញ្ជនៈ ៨ តួគឺ ញណនមយលវឡ ដូចជា តញ្ហា តណ្ហា តម្ហា មយ្ហំ វុល្ហំ ជិវ្ហា រូឡ្ហំ ដូច្នេះក៏ក្លាយទៅជា ឧរជ មានសំឡេងកើតក្នុងដើមទ្រូងទៅវិញ អក្ខរៈ ហនេះជួនណាជាកណ្ឋជៈ ជួនណាជាឧរជ ។

## ករណៈ

### ករណៈគឺលំនាំនៃការធ្វើសំឡេងមាន ៤ យ៉ាងគឺ=

១– ជិវ្ហាមជ្ឈ ពាក់កណ្ដាលអណ្ដាត សំរាប់អក្ខរៈជាតាលុជៈ

២– ជិវ្ហោបគ្គ រលាស់ចុងអណ្ដាតចូល សំរាប់អក្ខរៈ ជាមុទ្ធជៈ

៣– ជិវ្ហគ្គំ ចុងអណ្ដាត សំរាប់អក្ខរៈជាទន្តជៈ

៤– សកដ្ឋានំ តាមឋានរបស់ខ្លួនស្រាប់ សំរាប់អក្ខរក្រៅពីតាលុជៈ មុទ្ធជ ទន្តជៈ ។

## ឃោសនិងអឃោសៈ

### អក្ខរៈ ១១ តួ គឺ=

កខ ចឆ ដឋ តថ បផស នេះជាអឃោស សំឡេងមិនគឹកង

### អក្ខរៈ ២១ តួគឺ=

គឃង ជឈញ ឌឍណ ទធន ពភម យរលវហឡ នេះជាឃោសៈ មានសំឡេងលាន់ឮគឹកកង ។ និគ្គហិតគឺ ំ នេះជាឃោសាឃោសវិមុត្តិ រួចផុតពីឃោសនិងអឃោស ។

## អក្ខរប្បភេទ

ប្រភេទជាគូៗ គ្នានៃសំឡេងអក្ខរៈ ដែលមានសូរទើទពីគ្នា ហៅជាអក្ខរប្បភេទ បើរាប់ជាគូមាន ៤ គូគឺ=

សិថិល និង ធនិត ជាគូ ១

ទីឃៈ និង រស្សៈ ជាគូ ១

គរុ និង លហុ ជាគូ ១

និគ្គហិត និង វិមុត្តិ ជាគូ ១

សម្ពន្ធ និង វវត្ថិតៈ ជាគូ ១ ។

អក្ខរ ១០ តួក្នុងវគ្គគឺ=

កគ ចជ ដឌ តទ បព នេះជាសិថិល មានសំឡេងធូរគឺឥត មានសំឡេងអក្សរ ហ ផ្សំផងទេ ។

អក្ខរ ១០ តួក្នុងវគ្គដែរគឺ=

ខឃ ឆឈ ឋឍ ថធ ផភ នេះជាធនិត មានសំឡេងតឹងគឺមាន សំឡេងអក្សរ ហ ផ្សំជាមួយផង ។

## ទីឃៈនិងរស្សៈ

បណ្ដាស្រៈទាំង ៨ នោះមានសំឡេងវែង៥ គឺៈ អា ឦ ឩ ឯ ឱ នេះទោះប្រើជាស្រៈពេញតួក្ដី ជាស្រៈប្រើផ្សំជាមួយព្យញ្ជនក្ដី ហៅជាទីឃ មានសំឡេងវែង ។ ស្រៈមានសំឡេងខ្លី ៣ តួគឺ អ ឥ ឧ នេះទោះប្រើជាស្រៈ ពេញតួក្ដី ជាស្រៈប្រើផ្សំជាមួយនឹងព្យញ្ជនៈក្ដី ហៅ

ថាស្រៈមានសំឡេងខ្លី ។

មួយទៀតស្រៈទាំង៣តួនេះគឺ អា ឯ ឪ បើមានអក្សរតម្រួតនៅពីខាងចុង ត្រូវពោលឲ្យមានសំឡេងស្រដៀងនឹងរស្ស ដូចជា ស្វាក្ខាតោ មេត្តា សេដ្ឋី សោយ្យា ឪតប្បំ ។

## និគ្គហិតនិងវិមុត្តិ

## និគ្គហិតមានសំឡេង ២ យ៉ាងគឺៈ

សំឡេង (អាំង) ដូចជា យំ តំ នំ នេះហៅថា អនុនាសិកន្តៈ សំឡេងជា (អាំ) យម តម នម នេះហៅថាមការន្ត, តែសព្វថ្ងៃនេះនិយមប្រើ អនុនាសិកន្តច្រើនជាង ។ អក្សរនេះកាលសូត្រ ឬអាន ត្រូវបង្អើបមាត់ឲ្យហើបលើសជាងប្រក្រតីដូចជា បាណា ឯសា ថេរោ ទុរោទា ជាដើមនេះហៅថា វិមុត្តិ ។

## គរុនិងលហុ

ស្រទីឃៈនោះក្តី ស្រៈរស្សៈ ដែលមានអក្សរតម្រួតនៅពីខាងចុងក្តី និគ្គហិតក្តី ហៅថា គរុ យូរ, ធ្ងន់ ។ ស្រៈរស្សៈសុទ្ធហៅថា លហុ ស្រាល, រហ័ស ។

## សម្ពន្ធនិងវិវត្តិតៈ

បាលីដែលបងតភ្ជាប់គ្នាជាបទសន្ធិ ដូចជា តុណ្ហី+អស្ស តភ្ជាប់គ្នាជា តុណ្ហស្ស , តត្រ+ឥមេ, ជាតត្រិមេ, តត្ត+អាយស្មន្តេ ជាតត្តាយស្មន្តេ ជាដើម ហៅថា សម្ពន្ធ បទដែលបងភ្ជាប់ ។

បទបាលីដែលញែកចេញពីបទសន្ធិ ដូចជា តុណ្ហី អស្ស តត្រ ឥមេ តត្ត អាយស្មន្តេ មិនបងភ្ជាប់ជាតុណ្ហស្ស តត្រិមេតត្តាយស្មន្តេ ដូច្នេះជាដើមហៅថា វិវត្តិត បទញែកចេញ ។

## អធិប្បាយសង្ខេប

អក្ខរប្បភេទនេះ ជាគោលសំខាន់បំផុត ក្នុងអក្សរសាស្ត្រ ពោះអក្សររបស់ជនជាតិណា ភាសាណា ក៏សុទ្ធតែមានអក្ខរប្បភេទជាគោលដូចគ្នា ព្រោះជាគ្រឿងបញ្ជាក់សូរសំឡេងសំដីភាសាទីមួយ ៗ ។

ក្នុងព្រះវិន័យ មានសេចក្តីបញ្ជាក់ថា បណ្តាអក្ខរប្បភេទទាំង ៩ គូនោះ ត្រូវអ្នកសូធ្យឬអ្នកអានប្រុងប្រយ័ត្ន កុំឲ្យភ្លាត់គូណាមួយ ប៉ុន្តែដែលត្រូវប្រយ័ត្នយ៉ាងម៉ឺងម៉ាត់កុំឲ្យភ្លាត់ឲ្យសោះនោះ តែពីរគូគឺ សិថិលនិងធនិតនិគ្គហិតនិងវិមុត្តិ ដ្បិតគូទាំងពីរនេះសំខាន់ជាងពួកឯទៀត កាលបើសូធ្យឬអានភ្លាត់ ពោះសិថិលជាធនិត ឬ ធនិតជាសិថិលក្តីនិគ្គហិតជាវិមុត្តិ

ឬវិមុត្តិជានិគ្គហិតក្តី យ៉ាងនេះទៅជាវិបត្តិខុសពេញទីហៅថា អក្ខរវិបត្តិ ប្រើការពុំកើតឡើយ ។

ការក្លាត់នោះ ខាងភាសាបាលី សិថិលជាធនិតដូចជា សុណោ-តុ ក្លាត់ជាសុណាថុ, នាគោក្លាត់ជានាឃោ; ធនិតជាសិថិលដូចជា ខមតិក្លាត់ជា កមតិ, ភន្តេក្លាត់ជា ពន្តេ ជាដើម ។

បើធៀបនឹងភាសាខ្មែរ សិថិលជាធនិត ដូចជាគុំក្លាត់ជាឃុំ គោក ក្លាត់ជាថោក; ធនិតជាសិថិលដូចជា ថាក្លាត់ជាតា ថោកក្លាត់ជាគោក ជាដើម ។ និគ្គហិតជាវិមុត្តិ ឬ វិមុត្តិជានិគ្គហិត ខាងភាសាបាលី និគ្គហិតជាវិមុត្តិដូចជា បត្តកល្លំ ក្លាត់ជា បត្តកល្លា; វិមុត្តិជានិគ្គហិត ដូចជាឯ-សា ញត្តិ ឬឯសំញត្តិ ឬក៏ឯសញត្តិជាដើម ។ បើធៀបនឹងភាសាខ្មែរ និគ្គហិតជាវិមុត្តិដូចជា ដំណាំ ក្លាជា ដាណា, វិមុត្តិជានិគ្គហិត ដូចជា ធានា ក្លាត់ជា ធំនំ ដូច្នេះហៅថា អក្ខរវិបត្តិប្រើការពុំកើតឡើយ ។

ឯអក្ខរប្បភេទ ៣ គូក្រៅនេះ ក៏ត្រូវតែប្រយ័ត្នកុំឲ្យក្លាត់ដែរ ប៉ុន្តែបើបែរជាក្លាត់ ដូចជា សុណាតុ ជាសុណាតុ (ទីឃៈជារស្សៈ) នក្ខមតិ ក្លាត់ជានខមតិ (គរុជាលហុ), យស្សាយស្មោ ក្លាត់ជា

អាយស្មាគោ ( សម្ពន្ធវិវត្តិតៈ ) ដូច្នេះមិនទាន់កាប់ថាជាវិបត្តិពេញទី គង់កាប់ថានៅយកជាការបាន គ្រាន់តែឈ្មោះថាសូត្រខ្ជីខ្ជាប៉ុណ្ណោះ ព្រោះនៅស្តាប់សេចក្តីបាន មិនវិបត្តិដល់ខូចសេចក្តីទេ ។ ប៉ុន្តែបើទុកជាដូច្នោះក៏ដោយ អ្នកសិក្សាត្រូវតែហាត់ព្យាយាមសូត្រ អានទិសនិយាយឲ្យបានត្រឹមត្រូវតាមខ្យល់សំឡេងអក្សរឲ្យបានទៀងទាត់ជានិច្ច ។

## កណ្ឌទី ២៤

## សីមា

### សីមាមាន ២ យ៉ាងគឺ=

១– ពទ្ធសីមា ដែនដែលសង្ឃចងសូត្របានដល់ខេត្តដែលសង្ឃកំ-ណត់យកដោយខ្លួនឯង ។

២–អពទ្ធសីមា ដែនដែលសង្ឃមិនបានចង បានដល់ខេត្តដែលគេកំណត់ឲ្យតាមប្រក្រតីរបស់ប្រទេស ឬមានបញ្ញត្តិដទៃដែលជាគ្រឿងកំ-ណត់ ។

សីមាទាំងពីរនេះហាមមិនឲ្យចងតូចពេក ទាល់តែភិក្ខុ ២១ រូបអង្គុយមិនចុះ ។ តែហាមមិនឲ្យចងធំពេកដល់ទៅ ៣ យោជន៍ ។

## និមិត្តនៃសីមាមាន ៨ យ៉ាងគឺ=

១—បព្វតោ ភ្នំដីសុទ្ធ, ភ្នំថ្មសុទ្ធ, ភ្នំដីលាយថ្ម,

២—បាសាណោ ថ្មសុទ្ធ ថ្មលាយគ្រួសធំប៉ុនក្បាលគោ, បែបតូចមានទម្ងន់ ៣២ បលៈគឺ ៦៤ នាឡិ,

៣—វនំ ព្រៃ យកព្រៃឈើដែលមានខ្លឹម ដូចដើមរាំងជាដើម ដុះក្រុមគ្នា ចំនួនបួនប្រាំដើម ។

៤—រុក្ខោ ដើមឈើ យកឈើដែលមានខ្លឹម១ដើមក៏បាន ។

៥—មគ្គោ ផ្លូវ យកផ្លូវដើរឬផ្លូវរទេះដែលនៅប្រើជានិច្ច ។

៦—វម្មិកោ ដំបូក យ៉ាងតូចមានកំពស់៨ធ្នាប់ទំហំប៉ុនស្នែងគោ ។

៧—នទី ស្ទឹង យកស្ទឹងដែលមានទឹកហូរ សូម្បីមិនមានភ្លៀងក៏មិនរីងខះ ។

៨—ឧទកំ ទឹក យកទឹកដែលដក់នៅនឹងមួយកន្លែង ដូចត្រពាំងបឹងនិងជាតស្រះ ។

## សីមាវិបត្តិដោយហេតុ៣ប្រការគឺ=

១—សីមាខ្វះនិមិត្ត

២—មានឆាយាជានិមិត្ត(១)

---

(១) ឆាយា ស្រមោល, ។

៣– សីមាគ្មាននិមិត្តសោះ ។

## ពទ្ធសីមាក្នុងសម័យនេះមាន៣យ៉ាងគឺ=

១– ខណ្ឌសីមា សីមាចងចំពោះពេញឧបោសថ,

២– មហាសីមា សីមាចងគ្រប់វត្តទាំងមូល ,

៣– សីមាចងពីរជាន់ ។

តែក្នុងគម្ពីរមហាវគ្គថាមាន ៤ គឺយក នទីបារសីមា គឺសីមាដែលសន្មតគ្របមាត់ស្ទឹងទាំងពីរខាងមួយថែមទៀត ។

## អពទ្ធសីមាមាន៣យ៉ាគឺ=

១– គាមសីមា ខេត្តស្រុក ខេត្តនិគម ដែលចំណែកអាណាចក្រកំណត់ទុកហៅថា និគមសីមា ។

២– សត្តព្ភន្តរសីមា ខេត្តព្រៃចម្ងាយ ៧អព្ភន្តរ,(១)

៣– ឧទកុក្ខេបសីមា ខេត្តសាមគ្គីមួយមានរយៈបាចទឹកនៃកម្លាំងមជ្ឈិមបុរសៗបន្ថែមសីមា សង្ករៈមកទៀតត្រូវជា ៤.គឺសីមាសង្កត់សីមា ។

កាលបើសម្មតិសីមា ត្រូវប្រជុំសង្ឃឲ្យនៅក្នុងខេត្តគឺ: ខាងក្នុងនិមិត្តទាំងអស់គ្នា ឬនាំឆន្ទរបស់ភិក្ខុអ្នកប្រជុំមិនបានមក ។ តាមទំនៀម

(១)— មួយអព្ភន្តរមាន ៧ ព្យាម ។

ដែលធ្វើសង្ឃកម្មនោះ គួរតែបាត់សាមណេរឬញោមវត្ត ឲ្យចាំឃ្មាំហាម ឃាត់ភិក្ខុដទៃ កុំឲ្យចូលទៅក្នុងវេលាដែលកំពុងធ្វើកម្មនោះ បើការសព្វគ្រប់ជុំព្រមអស់ហើយ គប្បីប្រាប់និមិត្តជាមុន ការប្រាប់និមិត្តនេះក្នុងគម្ពីរ (វិមតិវិនោទនី) បានណែនាំថា ការប្រាប់និមិត្តនោះសង្ឃមិនបាច់លើកគ្នាទៅទាំងអស់ សន្មតយកតែ ៤ រូប ដើម្បីគ្រប់ចំនួនជាសង្ឃប៉ុណ្ណោះបាន ក្រៅពីនោះចាំក្នុងឧបោសថ ភិក្ខុមួយរូបជាអ្នកសួរ ត្រូវសួរពីទិសបូព៌ាជាលំដាប់ ទិសសួរនិមិត្តទិសណា ត្រូវឈរពីខាងក្នុង ឲ្យឃ្លាតល្មមមើលឃើញ បែរមុខទៅរកនិមិត្តនោះ រួចហើយពោលពាក្យសួរតាមឈ្មោះទិស ទិសសំដែងចំពោះទិសបូព៌ាទុកជាឧទាហរណ៍ថា បុរត្ថិមាយ ទិសាយ កិំ និមិត្តំ? ប្រែថា ទិសបូព៌ាមានអ្វីជានិមិត្ត ? ។

## កណ្ឌទី ២៥

## ភ្នាក់ងារធ្វើការសង្ឃ

ភិក្ខុដែលបានទទួលសម្មតិត្រូវប្រកបអង្គ ៥ គឺ=

១– ជាអ្នកមិនលំអៀង ព្រោះស្រឡាញ់

២– ជាអ្នកមិនលំអៀង ព្រោះស្អប់

៣– ជាអ្នកមិនលំអៀង ព្រោះល្ងង់

៤— ជាអ្នកមិនលំអៀង ព្រោះខ្លាច

៥— ជាអ្នកចូលចិត្តធ្វើក្នុងនាទីនោះ ៗ ដែលសង្ឃបានសន្មតឲ្យ ហើយនោះផង ។

## ភ្នាក់ងារធ្វើការសង្ឃមាន៥ប្រភេទគឺ=

១— ចៅអធិការនៃចីវរ

២— ចៅអធិការនៃអាហារ

៣— ចៅអធិការនៃសេនាសនៈ

៤— ចៅអធិការនៃអារាម

៥— ចៅអធិការនៃឃ្លាំង ។

## ចៅអធិករនៃចីវរមាននាទី ៣ យ៉ាងគឺ=

១— ចីវរប្បដិគ្គាហក មាននាទីទទួលចីវរ

២— ចីវរនិទាហក មាននាទីទុកចីវរ

៣— ចីវរភាជនកៈ មាននាទីចែកចីវរ ។

## ចីវរប្បដិគ្គាហក នោះគប្បីដឹងដូច្នេះគឺ=

ក) ចីវរដែលថ្វាយដល់សង្ឃ ដែលខ្លួនមាននាទីឧបដ្ឋាកនោះ

គួរទទួលទុក,

ខ)ចីវរដែលថ្វាយដល់សង្ឃ ខ្លួនមិនមាននាទីឧបដ្ឋាក នោះគេថ្វាយចំពោះបុគ្គលមិនគួរទទួល,

គ)ចីវរប្រភេទណា មានប៉ុន្មាន ទទួលទុកក្តី មិនបានទទួលទុកក្តី គួរកំណត់ចាំទុកឲ្យច្បាស់ ។

## របស់ដែលគេថ្វាយដល់សង្ឃ ឈ្មោះគឺ=

ក) ខ្ញុំម្ចាស់ថ្វាយក្នុងសីមាឬដល់សីមា

ខ) ខ្ញុំម្ចាស់ថ្វាយតាមកតិការបស់សង្ឃ

គ) ខ្ញុំម្ចាស់ថ្វាយដល់សង្ឃ

ឃ) ខ្ញុំម្ចាស់ថ្វាយដល់សង្ឃដែលបាំវស្សា ។

## ចីវរនិទាហក គប្បីដឹងឈ្មោះគឺ=

ក) គួរលះបង់អគតិទាំង ៤ ប្រការ

ខ)គប្បីដឹងនៅចីវរដែលគួរទុក និងមិនគួរទុក

គ) ចីវរដែលនាំយកថ្វាយ ដើម្បីជាសំពត់ចំណាំវស្សាដែលហៅថាអច្ចេកចីវរ គួរទុករហូតដល់ចេញវស្សា ហើយចែកដល់ភិក្ខុដែលចាំវស្សា

ឃ) ចីវរដែលទាយកប្រគេនមិនគ្រប់គ្នា ទុកចាំបានមកដែលល្មមនឹងចែកគ្នាគ្រប់ ។

ង) ចីវរដែលទាយកប្រគេនគ្រប់គ្នា ដែលមិនមែនជាអច្ចេកចីវរ គួរចែកគ្នាភ្លាមៗ ។

ច) ចីវរមានចំនួនប៉ុន្មាន ទុកដាក់ហើយក្តី ចែកទៅហើយក្តី គួរចាំទុកឲ្យប្រាកដ ។

## ចីវរភាជនអ្នកចែកចីវរគប្បីដឹងដូច្នេះគឺ=

ក) គប្បីលះបង់នូវអគតិទាំង ៤ ប្រការ

ខ) គប្បីស្គាល់នូវចីវរដែលគួរចែក នឹងមិនគួរចែក

គ) ចីវរដែលទាយកថ្វាយមិននិយមជាពិសេស មានចំនួនល្មមចែកបានគ្រប់គ្នាជារបស់គួរចែក,

ឃ) ចីវរដែលទាយកថ្វាយជាសំពត់កឋិនក្តី ជាតម្លៃនៃសេនាសនប្បច្ច័យក្តីមិនគួរចែក ។

ង) ចីវរមានចំនួនប៉ុន្មាន ចែកទៅហើយឬនៅឡើយក្តី គួរចាំទុក ។

## ចៅអធិការនៃអាហារមាននាទី ៤ យ៉ាងគឺ=

១– ភត្តុទ្ទេសក ជាអ្នកចែកភត្ត

២– យាគូភាជក ជាអ្នកចែកបបរ

៣– ផលភាជក ជាអ្នកចែកផ្លែឈើ

៤– ខជ្ជកភាជក ជាអ្នកចែកគ្រឿងបរិភោគផ្សេង ៗ ។

## ម៉្យាងទៀត

ក) គប្បីលះបង់នូវអគតិទាំង ៤ ប្រការ

១) គប្បីស្គាល់ភត្តដែលគួរចែកនិងមិនគួរចែក

គ) ភត្តមិននិយមគួរចែក

ឃ) ភត្តនិយមមិនគួរចែក ។

## ភត្តនិយមមា ៤ យ៉ាងគឺ=

១– អាគន្តុកភត្ត ភត្តដែលគេវេរដល់ភិក្ខុសង្ឃដែលទើបមកដល់ថ្មី

២– គមិកភត្ត ភត្តដែលគេវេរដល់ភិក្ខុសង្ឃដែលមានដំណើរនឹងទៅកាន់ទីណាមួយ,

៣– គិលានភត្ត ភត្តដែលគេវេរដល់ភិក្ខុសង្ឃដែលមានជម្ងឺ,

៤– គិលានុបដ្ឋាកភត្ត ភត្តដែលគេវេរដល់ភិក្ខុសង្ឃជាអ្នករក្សាជម្ងឺភិក្ខុ-សាមណេរផងគ្នា ។

## ការចែកភត្តមា ២ យ៉ាងគឺ=

១– ចែកភត្តដែលគេនាំមកប្រគេន

២– ចែកភត្តដែលគេនិមន្តទៅទទួលយកមកបានហើយ ។

## ភត្តដែលមានឈ្មោះ ៧ យ៉ាងគឺ –

១– សង្ឃភត្ត អាហារថ្វាយដល់សង្ឃ

២– ឧទ្ទេសភត្ត អាហារឧទ្ទិសសង្ឃ

៣– និមន្តភត្ត អាហារបានក្នុងទីនិមន្ត

៤– សលាកភត្ត អាហារថ្វាយតាមស្លាក

៥– បក្ខិកភត្ត អាហារថ្វាយតាមបក្ស(១)

៦– ឧបោសថិកភត្ត អាហារថ្វាយក្នុងថ្ងៃឧបោសថ

៧– បាដិបទិកភត្ត អាហារថ្វាយក្នុងថ្ងៃជាបាដិបទគឺថ្ងៃ ១ កើតឬ ថ្ងៃ ១ រោច ។

## ចៅអធិការនៃសេនាសនមាន ២ យ៉ាងគឺ=

១– សេនាសនគ្គាហាបក អ្នកចែកសេនាសន

---

(១)បក្សមានពីរគឺសុក្កបក្ខ ចំណែកខាងខ្នើត, កាឡបក្ខ ចំណែកខាងរនោច ។

២– សេនាសនប្បញ្ញាបក អ្នកតែងតាំងសេនាសនៈ ។

## ចៅអធិការនៃអារាមមាននាទី ៣ យ៉ាងគឺ=

១- អារាមិកបេសក ជាអ្នកប្រើមនុស្សឲ្យធ្វើការវត្ត

២– សាមណេរបេសក ជាអ្នកប្រើសាមណេរ

៣– នវកម្មិក ជាអ្នកមើលនវកម្មគឺការកសាង ។

## ចៅអធិការនៃឃ្លាំងមាននាទី ២ យ៉ាងគឺ=

១– ភណ្ឌាគារិក ជាអ្នករក្សាភ័ស្តុការរបស់សង្ឃ

២– អប្បមត្តកវិស្សជ្ជក ជាអ្នកចែករបស់បន្តិចបន្តួចដល់សង្ឃ ។

រឿងនេះនឹងឲ្យភិក្ខុមួយរូបទទួលនាទីទាំង ២ នឹងសម្មតិក្នុងកម្មវាចា ជាមួយគ្នាក៏បាន ។

## ក្នុងសេនាសនក្ខន្ធកមានសម្មតិ ២ យ៉ាងទៀតគឺ=

១- សាដិយគ្គាហាបក ជាអ្នកទទួលសាដិកា

២- បត្តគ្គាហាបក ជាអ្នកឲ្យទទួលបាត្រ ។

នឹងសម្មតិសេនាសនគ្គាហាបក តែ ១ រូបមិនគួរៗតែសម្មតិ ២ រូបដើម្បីជួយគ្នា ចែកជួយគ្នារក្សា ដូចជាព្រះវិហារជាកន្លែងធំគួរតែឲ្យមានគ្នា

ច្រើន ៗ

# កណ្ឌទី ២៦

## កឋិន

### សំពត់ដែលគួរក្រាលកឋិនមាន ៥ យ៉ាងគឺ=

១– សំពត់ថ្មី

២ –សំពត់ទៀបថ្មី

៣–សំពត់ចាស់

៤– សំពត់បង្សុកូល

៥– សំពត់ធ្លាក់តាមរានផ្សារ ៗ

អ្នកថ្វាយកឋិនសុទ្ធរឹបព្វជិត ឬក៏គ្រហស្ថក៏បាន ៗ

### សំពត់មិនគួរក្រាលកឋិនមាន ៥ យ៉ាងគឺ=

១– សំពត់ដែលមិនមែនជាសិទ្ធិ

២ – សំពត់ដែលបានមកដោយអាការធ្វើនិមិត្ត

៣ – សំពត់ដែលបានមកដោយនិយាយបញ្ចិតបញ្ចៀន

៤– សំពត់ត្រូវនិស្សគ្គិយ៍

៥— សំពត់ទុកឲ្យកន្ទេនពត្រើ ។

ភិក្ខុប្រកបដោយអង្គ ៨ ប្រការគួរឲ្យក្រាលកឋិន

## អង្គ ៨ ប្រការនោះគឺ—

១— ចេះបុព្វករណ៍

២— ចេះដកត្រៃចីវរ

៣— ចេះអធិដ្ឋានត្រៃចីវរ

៤— ចេះក្រាលកឋិន

៥— ចេះមាតិកា

៦— ចេះបលិពោធ ដោយហេតុនៅមិនដោះកឋិន

៧— ដឹងនៅហេតុដោះកឋិន

៨— ស្គាល់អានិសង្សកឋិន ។

## បុព្វករណ៍មាន ៧ យ៉ាងគឺ—

១— បោកគក់សំពត់

២— វាស់សំពត់

៣— កាត់សំពត់

៤ - ផុលភ្ជាប់សំពត់

៥- ដេរជាចីវរ

៦- ជ្រលក់ចីវរដែលដេរហើយ

៧- ធ្វើវិកប្ប-ពិន្ទុ ។

## ដកត្រៃចីវរថាដូច្នេះ

សំពត់សង្ឃាដីថា ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ(១)

សំពត់ចីវរថា ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ

សំពត់ស្បង់ថា ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ ។

## អធិដ្ឋានត្រៃចីវរថាដូច្នេះ

សំពត់សង្ឃាដីថា ឥមំ សង្ឃាដឹ អធិដ្ឋានមិ(១)

សំពត់ចីវរថា ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ

សំពត់ស្បង់ថា ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។

## ពាក្យក្រាលកឋិនថាដូច្នេះ

---

១ — ប្រែថា អាត្មាអញដកនូវសំពត់សង្ឃាដីនេះ, ស្បង់និងចីវរមានន័យដូចគ្នា គ្រាន់តែចេញឈ្មោះថាចីវរ-ស្បង់ប៉ុណ្ណោះ ។ ២- ប្រែថាអាត្មាអញតាំងទុកនូវសំពត់សង្ឃាដីនេះ,ស្បង់និងចីវរមានន័យដូចគ្នា ។

សំពត់សង្ឃាដីថា ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ(១)

សំពត់ចីវរថា ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ

សំពត់ស្បង់ថា ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ ។

## មាតិកា ៨ នោះគឺ =

១– កំណត់ដោយការចេញទៅៗ ដោយគិតថានឹងមិនត្រឡប់

២– កំណត់ដោយធ្វើចីវរស្រេចហើយ

៣– កំណត់ដោយសន្និដ្ឋានថានឹងមិនធ្វើ

៤ កំណត់ដោយការខូចឬបាត់

៥– កំណត់ដោយអស់សង្ឃឹម

៦– កំណត់ដោយបានឮដឹង

៧– កំណត់ដោយអស់ខេត្ត

៨– កំណត់ដោះព្រមជាមួយនឹងភិក្ខុទាំងឡាយ ។

## អនុមោទនាកឋិន

អត្ថតំ { អាវុសោ / ភន្តេ } សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោ { ទថ / ទាមិ }

---

១– ប្រែថាអាត្មាអាញក្រាលនូវសំពត់សង្ឃាដីនេះ, ស្បង់និងចីវរមានន័យដូចគ្នា ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ កឋិនរបស់សង្ឃក្រាលហើយ ការក្រាលកឋិនជាធម៌ត្រឹមត្រូវ តាមរបៀបហើយ ចូរភិក្ខុទាំងឡាយអនុមោទនាចុះ ។

## បលិពោធ ២ យ៉ាងគឺ=

១– អាវាសបលិពោធ បលិពោធក្នុងអាវាស

២– ចីវរបលិពោធ បលិពោធក្នុងចីវរ ។

## អធិប្បាយបលិពោធ ២ យ៉ាង

ភិក្ខុនៅក្នុងអាវាសនោះឬចេញទៅ ដោយចងចិត្តថានឹងត្រឡប់មកវិញ ឈ្មោះថានៅមានអាវាសបលិពោធ, ភិក្ខុចេញទៅអំពីអាវាសនោះ ដោយដាក់ធុរៈថា នឹងមិនត្រឡប់មកវិញ ឈ្មោះថាអាវាសបលិពោធដាច់ ។ ភិក្ខុនៅមិនទាន់បានធ្វើចីវរនៅឡើយ ឬធ្វើមិនទាន់ហើយ ឬបាត់ក្នុងវេលាធ្វើនោះ តែមិនទាន់អស់សង្ឃឹមថានឹងបានចីវរមកទៀត ឈ្មោះថានៅមានចីវរបលិពោធ, ភិក្ខុធ្វើចីវរស្រេចហើយ ឬកំពុងធ្វើនោះបាត់ ឬអន្តរាយមានភ្លើងឆេះជាដើម អស់សេចក្តីសង្ឃឹមថា នឹងបានមកទៀត ឈ្មោះថាចីវរបលិពោធដាច់ ។

បលិពោធទាំងពីរនេះ ណាមួយមាននៅអាចរក្សាអានិសង្សកឋិននឹងខេត្តនៃចីវរកាលឲ្យប្រព្រឹត្តទៅតាមកំណត់នោះ បើដាច់ព្រមទាំងពីរប្រការ

ហើយ ឈ្មោះថាអស់អានិសង្សកឋិន អស់ខេត្តចីវរកាល ហៅថា ដោះកឋិន ។

## អានិសង្ស ៥ យ៉ាងគឺ=

១– ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា តាមសិក្ខាបទទី៦នៃអចេលកវគ្គ បាចិត្តិយកណ្ឌ ។

២– ត្រាច់ទៅណាមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់

៣– ឆាន់គណភោជននិងបរម្បរភោជនបាន

៤– ទុកដាក់អតិរេកចីវរតាមសេចក្ដីត្រូវការ

៥– ចីវរដែលកើតឡើងក្នុងទីនោះ ជារបស់ត្រូវបានដល់ភិក្ខុទាំងឡាយនោះ ។ ខេត្តនៃចីវរកាលនេះមានរហូត ៤ ខែនៃហេមន្តរដូវ ។

## កណ្ឌទី២៧

## បព្វជ្ជានិងឧបសម្បទា

បព្វជ្ជាសព្ទនេះ សំដៅយកការបួសទូទៅ រួមឧបសម្បទផងក៏មាន សំដៅយកការបួស ដែលជាបុព្វយោគនៃឧបសម្បទ រួមទាំងការបួស ទំ-នងជាសាមណេរក៏មាន បានសេចក្ដីថា សាវករូបមួយៗ បានទទួលទាំងពីរយ៉ាងនេះ ។

## បព្វជ្ជាដោយទ្រៃសរណគមន៍ ២ បែបគឺ=

១– ការឲ្យគ្រងសំពត់កាសាយៈ ឈ្មោះថាឲ្យបព្វជ្ជា

២– ការឲ្យទទួលសរណគមន៍ ឈ្មោះថាឲ្យឧបសម្បទ ។

## បព្វជ្ជាដោយឯហិភិក្ខុ ២ បែបគឺ=

១– ទ្រង់ត្រាស់ថា ចូរកើតជាភិក្ខុមកចុះ ប៉ុណ្ណោះឈ្មោះថាទ្រង់ប្រទានបព្វជ្ជា ។

២– ទ្រង់ត្រាស់ថា ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ប៉ុណ្ណោះឈ្មោះថាទ្រង់ប្រទានឧបសម្បទ ។

## វិធីប្រាប់ភណ្ឌុកម្ម

ប្រាប់ដោយខ្លួនឯងថា សង្ឃំ ភន្តេ ឥមស្ស ទារកស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ,(១) ប្រែថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ប្រាប់ភណ្ឌុកម្មនៃទារកនេះដល់សង្ឃ ។ ផ្ដាំភិក្ខុដទៃឲ្យទៅប្រាប់ថា ឯកោ ភន្តេ បព្វជ្ជាបេក្ខោ អត្ថិ តស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ(១), ប្រែថា បពិត្រលោកម្ចាស់ បព្វជ្ជាបេក្ខមានម្នាក់ខ្ញុំម្ចាស់ប្រាប់ភណ្ឌុកម្មឲ្យគេ ។

---

១- ទុតិយម្បិ . . . តតិយម្បិ . . . ។

២- ទុតិយម្បិ . . . តតិយម្បិ . . . ។

# មនុស្សដែលហាមមិនឱ្យបព្វជ្ជាមាន ៨ ចំពូកគឺ

១– មនុស្សកើតកេតឃ្លង់, ឬសអុត, អុតស្វាយ, ស្រែង, ហើតធ្លួតជ្រុក,

២–មនុស្សមានអវៃយវៈខ្វះខាតដូចជាដៃជើងកំបុតជាដើម

៣– មនុស្សមានអវៃយវៈ មិនសមប្រកប ដូចជាមនុស្សតាបហួសប្រមាណជាដើម,

៤–មនុស្សពិការដូចជាខ្វាក់ ខ្វាក់ស

៥– មនុស្សទុព្វលភាព គឺមនុស្សគម

៦– មនុស្សជាប់ជំពាក់ គឺមាតាបិតាមិនអនុញ្ញាតជាដើម

៧– មនុស្សធ្លាប់ជាប់ទោសព្រះរាជអាជ្ញា

៨– មនុស្សប្រទូសរ៉ាយ និងសេចក្តីស្ងប់គឺធ្វើចោរកម្មជាដើម ។

## ឧបសម្បទ

បុគ្គលដែលសង្ឃនឹងឲ្យឧបសម្បទបានត្រូវប្រកបដោយសម្បត្តិ ២ យ៉ាងគឺ :

១– ជាប្រុសមានអាយុ ២០ ឆ្នាំ បរិបូណ៌

២– មិនមែនជាអភព្វបុគ្គលដែលត្រូវហាម ។

# វិធីរាប់អាយុ

រាប់តាំងពីបដិសន្ធិមក បើមិនចាំប្រាកដឲ្យរាប់កាលដែលនៅក្នុងគភ៌ត្រឹម៩ខែយ៉ាងច្រើន តិចជាងនោះមិនបាច់និយាយ ការរាប់អាយុគប្បីរាប់គំរប់ខែកើតជា១ឆ្នាំ រាប់ឲ្យបាន១៩ជុំនឹង៣ខែយ៉ាងតិចថែម៩ខែដែលនៅក្នុងគភ៌ទៀតត្រូវជា២០ ឆ្នាំបរិបូណ៌ មនុស្សមានអាយុតិចជាង២០ឆ្នាំបួសមិនឡើងជាភិក្ខុភាព ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយភិក្ខុក្រៅពីនោះត្រូវអាបត្តិទុក្កដ, មិនដឹងឬសំគាល់ខុសមិនត្រូវអាបត្តិ តែកុលបុត្រនោះក៏នៅតែមិនកើតជាភិក្ខុទៅបាន ។

## អភព្វបុគ្គល ៣ ចំពូកគឺ=

១– មនុស្សមានភេទខ្វះខាត

២– មនុស្សប្រព្រឹត្តខុសធម៌វិន័យ

៣– មនុស្សប្រព្រឹត្តខុសនឹងកំណើតរបស់ខ្លួន ។

## មនុស្សមានភេទខ្វះខាតមាន ២ចំពូកគឺ=

១– បណ្ឌក មនុស្សខ្ទើយ

២– ឧភតោព្យញ្ជនក មនុស្សមានភេទពីរ ។

បណ្ឌកគឺបានដល់បុរសដែលមានរាគច្រើន ប្រព្រឹត្តខុសខាងផ្លូវសេពកាម

អាចល្បួងបុរសដទៃឲ្យប្រព្រឹត្តដូច្នោះ១, ខ្ទើយពីកំណើត១, ។

ឧភតោព្យញ្ជនក គឺបានដល់បុរសឬស្ត្រីពីកំណើត ។

## មនុស្សប្រព្រឹត្តខុសនឹងធម៌វិន័យមាន ៧ ចំពូកគឺ=

១– សម្លាប់ព្រះអរហន្ត

២– ប្រទូសរ៉ាយភិក្ខុនី

៣– មនុស្សលួចភេទ

៤– ចូលតីរ្ថិយ៍ទាំងភិក្ខុ

៥– ត្រូវអាបត្តិបារាជិកកាលនៅជាភិក្ខុ

៦– ភិក្ខុធ្វើសង្ឃភេទ

៧– ប្រទូសរ៉ាយព្រះសម្ពុទ្ធរហូតដល់ញុាំងព្រះលោហិតឲ្យចេញ ។

## មនុស្សប្រព្រឹត្តខុសនឹងកំណើតរបស់ខ្លួនមានពីរចំពូកគឺ=

១ –សម្លាប់មាតា

២– សម្លាប់បិតា ។

អភព្វបុគ្គលទាំងអស់នោះ បើបានដឹងមកហើយមិនគួរឲ្យបួស បើ

បួសរួចហើយទើបដឹងជាក្រោយ គប្បីនាសនៈចេញចាកគណៈភ្លាម ។

## មនុស្សដែលត្រូវហាមមិនឱយបួសមាន ៣ ពួកគឺ

១– មនុស្សមិនមានឧបជ្ឈាយ៍ ឬមានតែជាមនុស្សដែលមិនមែន
ជាភិក្ខុ ឬយកសង្ឃយកគណៈជាឧបជ្ឈាយ៍,

២– មនុស្សមិនមានបាត្រចីវរ

៣– មនុស្សខ្ចីបាត្រខ្ចីចីវរគេមក ។

## បុព្វកិច្ចនៃឧបសម្បទមាន ១0 យ៉ាងគឺ=

១– ឲ្យបព្វជ្ជា

២– សុំនិស្ស័យ

៣– កាន់យកព្រះឧបជ្ឈាយ៍

៤– សម្មតិនាមឧបសម្បទាបេក្ខជាមគធភាសា

៥– ប្រាប់បាត្រនិងចីវរ

៦– បង្គាប់ឲ្យឧបសម្បទាបេក្ខ ចេញទៅឈរខាងក្រៅឃ្លាតពីការក
សង្ឃ

៧– សម្មតិឲ្យភិក្ខុមួយរូបទៅសាកសួរអន្តរាយិកធម៌

៨– ហៅឧបសម្បទាបេក្ខឲ្យចូលមកក្នុងជំនុំសង្ឃ

៩– ឧបសម្បទាសុំឧបសម្បទ

១០– ភិក្ខុមួយរូបសាកសួរអន្តរាយិកធម៌កណ្តាលជំនុំសង្ឃ ។

មច្ឆិមកិច្ចនៃឧបសម្ប័ន្នមាន ៦ យ៉ាងគឺ=

១– វាស់ស្រមោល

២– ប្រាប់រដូវ

៣– ប្រាប់ថ្ងៃ

៤– ប្រាប់សង្គីតិ

៥– ប្រាប់និស្ស័យ

៦– ប្រាប់អករណីយកិច្ច ។

## កណ្ឌទី ២៨

## វិធីរម្ងាប់អធិករណ៍

## វិវាទាធិករណ៍

វិវាទដែលចាត់ជាអធិករណ៍ ចំពោះវិវាទដែលប្រារព្ធអំពីធម៌និងវិន័យ ក្នុងបាលីចាត់ជាគូមាន ៩ គូ បើរាប់រាយមាន ១៨ ហៅថាអដ្ឋារសភេទករវត្ថុ ប្រែថារឿងធ្វើសេចក្ដីប្រេះឆារ ១៨ យ៉ាង,

អដ្ឋារសភេទករវត្ថុដែលចាត់ជា ៩ គូនោះគឺ=

១– វិវាទគ្នាថានេះជាធម៌ នេះមិនមែនជាធម៌

២— វិវាទគ្នាថានេះជាវិន័យ នេះមិនមែនជាវិន័យ

៣— នេះព្រះតថាគតទ្រង់ភាសិតទុក នេះមិនមែនទ្រង់ភាសិតទុក

៤— នេះព្រះតថាគតទ្រង់ប្រព្រឹត្តមក នេះមិនទ្រង់ប្រព្រឹត្តមក

៥— នេះព្រះតថាគតទ្រង់បញ្ញត្តិទុក នេះមិនមែនទ្រង់បញ្ញត្តិទុក

៦— នេះជាអាបត្តិ នេះមិនមែនជាអាបត្តិ

៧— នេះអាបត្តិស្រាល នេះអាបត្តិធ្ងន់

៨— នេះជាអាបត្តិមានចំណែកសល់ នេះមិនមែនជាអាបត្តិមានចំណែកសល់

៩— នេះជាអាបត្តិមានទោសអាក្រក់ នេះមិនមែនជាអាបត្តិមានទោសអាក្រក់

## ការបង្កើតវិវាទមាន ២ យ៉ាងគឺ=

១— បង្កើតវិវាទព្រោះឃើញដល់ធម្មវិន័យ ឈ្មោះថាធ្វើដោយប្រាថ្នាល្អ

២— បង្កើតវិវាទព្រោះទិដ្ឋិ មានះឈ្មោះថាធ្វើដោយប្រាថ្នាអាក្រក់ ថោកទាប ,

## អ្នកធ្វើដោយប្រាថ្នាល្អមាន ៣ យ៉ាងគឺ=

១- មានចិត្តប្រកបដោយអលោភ;

២- មានចិត្តប្រកបដោយអទោស:

៣- មានចិត្តប្រកបដោយអមោហ: ។

## អ្នកធ្វើដោយប្រាថ្នាអាក្រក់ថោកទាបមាន ៦ គូគឺ=

១- ជាអ្នកមានសន្តានចិត្តក្រោធ ជាអ្នកប្រកាន់ក្រោធ

២- ជាអ្នករមិលគុណលោក ជាអ្នកមានខ្លួនស្មើ

៣ ជាអ្នកឥស្សា ជាអ្នកកំណាញ់

៤- ជាអ្នកអួតអាង ជាអ្នកមាយា

៥- ជាអ្នកប្រាថ្នាលាមក មានសេចក្តីឃើញខុស

៦- ជាអ្នកប្រកាន់យកតែសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ ដែលនឹងដកបានដោយកម្រ ។

រួមជាអ្នកមានចិត្តប្រកបដោយ លោភ: ទោស: មោហ: ។

## វត្ថុ ១០ យ៉ាងរបស់វជ្ជីបុត្រ

១- ការទុកអំបិលក្នុងក្អាក់ ត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់ភោជនជាសន្និធិ ហៅឲ្យខ្លីថា រឿងអំបិលក្នុងក្អាក់,

២- ស្រមោលជ្រេទៅហើយពីរធ្នាប់ឆាន់ភោជន ត្រូវអាបត្តិបាចិ-

ត្តិយ ព្រោះឆាន់ភោជនក្នុងវេលាវិកាល ហៅឲ្យខ្ញីថា រឿងពីរធ្លាប់,

៣– ឆាន់រួចហើយ ឃាត់ភត្តហើយ ចូលទៅកាន់បន្ទោះផ្ទះត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់ភោជនជាអនតិរិត្ត ហៅឲ្យខ្ញីថា រឿងចូលទៅកាន់បន្ទាះផ្ទះ ។

៤– ក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើឧបោសថ ត្រូវអាបត្តិទុក្កដ ព្រោះល្មើសវិន័យ ហៅឲ្យខ្ញីថា រឿងអាវាស

៥–ធ្វើសង្ឃកម្ម មិនព្រមគ្នា ត្រូវអាបត្តិទុក្កដ ព្រោះល្មើសវិន័យ ហៅឲ្យខ្ញីថា រឿងអនុមតិ,

៦–ប្រព្រឹត្តតាមទំនៀម ឧបជ្ឈាយ៍ អាចារ្យ ខ្លះគួរខ្លះមិនគួរហៅឲ្យខ្ញីថា រឿងធ្លាប់ប្រព្រឹត្តមក,

៧– ទឹកដោះស្រស់ប្រែជាទធិហើយ ភិក្ខុឃាត់អាហារហើយ ឆាន់ទៀតត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់ភោជនជាអនតិរិត្ត ហៅឲ្យខ្ញីថា រឿងមិនបានម្ចាស់,

៨– ផឹកសុរាយ៉ាងទន់មានពណ៌ក្រហមដូចជើងព្រាប ត្រូវអាបត្តិបាចិត្តិយ ព្រោះសុរាមេរ័យ,

៩–សំពត់និសីទនមិនមានជាយត្រូវអាបត្តិបាចិត្តិយត្រូវតែកាត់ចេញ

១០– ទទួលមាសនឹងប្រាក់ ត្រូវអាបត្តិបាចិត្តិយ ។

វត្ថុ ១០ ប្រការនេះ ពួកភិក្ខុវជ្ជីបុត្រនាំគ្នាយល់ឃើញថាអាចប្រព្រឹត្តបានទាំងអស់ ផ្ទុយគ្នានឹងព្រះពុទ្ធដីកា ព្រោះមានព្រះពុទ្ធប្បញ្ញត្តិហាមមកគ្រប់ៗ ខថាមិនគួរប្រព្រឹត្តឡើយ ។

## កិរិយាការពារមិនឱ្យវិវាទាធិករណ៍កើតឡើងមាន៣យ៉ាងគឺ=

១– ក្នុងផ្លូវធម៌ ព្រះសាស្ដាបានទ្រង់សម្ដែងនូវទបាតិមោក្ខ ដែលសរដល់ជីវិតនៃព្រះសាសនា ក្នុងទប្រជុំសង្ឃជានិច្ច,

២ – ក្នុងផ្លូវព្រះវិន័យព្រះអង្គបានទ្រង់តាំងទំនៀមឲ្យធ្វើសង្ឃឧបោសថដោយការសូត្របាតិមោក្ខរាល់កន្លះខែ,

៣– ការធ្វើសង្គាយនា ព្រះធម៌វិន័យ ដែលព្រះសាវកប្រកាន់ជានិច្ចសំខាន់បំផុត បាននាំគ្នាធ្វើមកក្នុងគ្រា ដែលវិបរិតហេតុដល់បានចារិកអក្សរទុកមកដល់សព្វថ្ងៃនេះ ។

## វិវាទាធិករណ៍រម្ងាប់ដោយសមថ២យ៉ាងគឺ=

១– សម្មុខាវិន័យ រម្ងាប់ចំពោះមុខ

២– យេភុយ្យសិកា រម្ងាប់ដោយធ្វើតាមទំនៀមនៃសេចក្ដីយល់ឃើញរបស់គេភាគច្រើន ។

## វិធីរម្ងាប់ដោយសម្មុខាវិន័យមាន ៣ យ៉ាងគឺ=

១— ដោយការព្រមព្រៀងគ្នាឯង

២— ដោយការតាំងឲ្យមានអ្នកវិនិច្ឆ័យ

៣— ដោយអំណាចនៃសង្ឃ ។

វិវាទាធិករណ៍រម្ងាប់ហើយ បើមានអ្នកណាមួយមករុសរើឡើងជាថ្មីទៀត ត្រូវអាបត្តិបាចិត្តិយ ។

## អង្គរបស់ភិក្ខុដែលគួរលើកឱយវិនិច្ឆ័យមាន ១០ យ៉ាងគឺ=

១— ជាអ្នកមានសីល

២— ជាពហុស្សុត

៣— ជាអ្នកទ្រទ្រង់បាតិមោក្ខ

៤— ជាអ្នកចាំទាំក្នុងវិន័យ

៥— ជាអ្នកអាចបន្ទុលផ្តាច់ ឲ្យគូក្តីចូលចិត្តនឹងជ្រះថ្លា

៦— ចេះកាត់អធិករណ៍

៧— ជាអ្នកឆ្លាតដើម្បីញ៉ាំងអធិករណ៍ឲ្យរម្ងាប់

៨— ស្គាល់រឿងអធិករណ៍

៩— ស្គាល់ហេតុកើតអធិករណ៍

១០— បេះគ្នងផ្លូវកាត់អធិករណ៍

## វិធីរម្ងាប់ដោយយេភុយ្យសិកា

ការរម្ងាប់ដោយវិធីនេះ សង្ឃគប្បីសន្មតភិក្ខុមួយរូបដែលប្រកបដោយអង្គ ៥ ជាអ្នកឲ្យពួកភិក្ខុចាប់ស្លាក គឺបោះឆ្នោតរើសដោយញត្តិទុតិយកម្មវាចា ។

## អង្គ ៥ នោះគឺ=

១— ជាអ្នកមិនដល់នូវឆន្ទាគតិ

២— ជាអ្នកមិនដល់នូវទោសាគតិ

៣— ជាអ្នកមិនដល់នូវមោហាគតិ

៤— ជាអ្នកមិនដល់នូវភយាគតិ

៥— ជាអ្នកស្គាល់ស្លាកដែលគួរចាប់ និងមិនគួរចាប់ ។

## វិធីចាប់ស្លាកមាន ៣ យ៉ាងគឺ=

១— ដោយការបិទបាំង

២— ដោយការខ្សឹប

៣— ដោយការប្រកាស ។

ឃើញថាសមដោយវិធីណាក៏គប្បីធ្វើដោយវិធីនោះ ភិក្ខុដែលនឹងស្តីការក្តីគប្បីប្រកបដោយអង្គ ៥ យ៉ាងគឺ=

១– ជាការដ៏សមគួរ

– ជារឿងពិតឬប្រាប់ថាពិត

៣– ជាការប្រកបដោយប្រយោជន៍

៤– នឹងបានភិក្ខុដែលធ្លាប់ឃើញគ្នា ធ្លាប់ជួបគ្នា ចូលជាបក្ខដោយធម្មវិន័យ

៥– សេចក្តីលំបាកក្នុងរឿងនេះនឹងមិនមានតទៅ ។

## កណ្ឌទី ២៩

## អនុវាទាធិករណ៍

អនុវាទៈ គឺការចោទដែលចាត់ជាអធិករណ៍នោះ ចំពោះការចោទដោយអាបត្តិដែលចែកជាវិបត្តិ ៤,

### ការចោទមាន ២ យ៉ាងគឺ=

១– ចោទដោយប្រាថ្នាល្អ

២– ចោទដោយប្រាថ្នាអាក្រក់ ។

## អង្គនៃការចោទជារឿងដែលមានមូល ៣ យ៉ាងគឺ=

១—រឿងដែលបានឃើញដោយខ្លួនឯង

២—រឿងដែលបានឮដោយខ្លួនឯង  ឬមានគេប្រាប់ហើយជឿថាជាការពិតដូច្នោះ ។

៣—រឿងក្រៅអំពីពីរស្ថានខាងលើតែមានរង្កៀសដោយអាការ,

## ក្ដីដែលគួរថាព្រមដោយអង្គ ៥ យ៉ាងគឺ=

១—ជាការដ៏សមគួរ

២—ជារឿងពិតឬប្រាកដជាមានរឿងពិត

៣—ជាការប្រកបដោយប្រយោជន៍

៤—នឹងបានភិក្ខុដែលធ្លាប់ឃើញគ្នា  ធ្លាប់ជួបគ្នាមូលជាបក្សខាងធម្មវិន័យ

៥—សេចក្ដីលំបាកនិងសេចក្ដីបែកបាក់  នៃសង្ឃអំពីរឿងនោះនឹងមិនអាចមាន ភិក្ខុដែលនឹងចោទភិក្ខុដទៃត្រូវតាំងនៅក្នុងធម៌ ៥ យ៉ាងគឺ=

១—និយាយដោយកាលៈទេសៈ

២—និយាយដោយពាក្យពិត

៣—និយាយដោយពាក្យសុភាព

៤—និយាយ តែពាក្យដែលប្រកបដោយប្រយោជន៍

៥—មានចិត្តមេត្តា ។

ម្យ៉ាងទៀតគប្បីមានធម៌ ៥ ប្រការគឺ=

១—សង្រ្គឹមសេចក្ដីករុណា

២—សេចក្ដីសង្រ្គឹមប្រយោជន៍

៣—ដោយសេចក្ដីអាណិត

៤—ដើម្បីចេញចាកអាបត្តិ

៥—លើកយក ធម៌វិន័យមកជាមុខ ។

ការចោទមាន ២ យ៉ាងគឺ=

១—ចោទដោយកាយ

២—ចោទដោយវាចា ។

អត្ថវិនិច្ឆ័យអធិករណ៍ មាន ៣ យ៉ាងគឺ=

១—សង្ឃ

២—គណៈ

៣—បុគ្គល ។

## របៀបភិក្ខុដែលនឹងចូលទៅកាន់ទីវិនិច្ឆ័យមាន ៧ យ៉ាងគឺ=

១– សង្រួមខ្លួន

២– គប្បីស្គាល់ទីអង្គុយ

៣– កុំគប្បីអង្គុយជ្រៀតបៀតនឹងព្រះថេរៈ

៤– កុំគប្បីអង្គុយជ្រៀតបៀតនឹងភិក្ខុខ្ចី

៥– គប្បីអង្គុយលើអាសនដ៏សមគួរ

៦– កុំគប្បីអង្គុយលើករឿងដទៃមកនិយាយ

៧– គប្បីរក្សាតុណ្ហីភាព ។

មុនដែលនឹងចោទនោះ ភិក្ខុជាអ្នកចោទ ក៏គប្បីសូមឱកាស ដល់អ្នកចម្លើយតាមរបៀបជាមុន, បើមិនសូមឱកាស ចោទតែម្តងនោះត្រូវអាបត្តិទុក្កដ ។

### ពាក្យសូមឱកាសចំពោះសង្ឃថា៖

ករោតុ មេ អាយស្មា ឱកាសំ អហន្តំ វត្តុកាមោ, ប្រែថា សូមលោកម្ចាស់ ចូរធ្វើឱកាសដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ប្រាថ្នានឹងចោទលោកម្ចាស់ ។

### ពាក្យឲ្យឱកាស

ករោមិ អាយស្មតោ ឱកាសំ, ប្រែថា ខ្ញុំធ្វើឲ្យដល់លោក

ម្ចាស់ ៗ

មិនគួរឱ្យឱកាសដល់ភិក្ខុដែលប្រកបដោយអង្គ ៥ យ៉ាងគឺ=

១— ជាអ្នកមានសេចក្តីប្រព្រឹត្តិដោយកាយមិនបរិសុទ្ធ

២— ជាអ្នកមានសេចក្តីប្រព្រឹត្តិដោយវាចាមិនបរិសុទ្ធ

៣— ជាអ្នកមានជីវមិនបរិសុទ្ធ

៤— ជាមនុស្សខ្លៅមិនឆ្លាត

៥— កាលបើគេសួរមិនអាចឆ្លើយត្រូវតាមពាក្យសួរ ៗ

មានអង្គ ៥ យ៉ាងទៀតគឺ=

១— ជាអលជ្ជី

២— ជាមនុស្សពាល

៣— មិនមែនជាបកតត្ត:

៤— ជាអ្នកមានសេចក្តីប្រាថ្នាមានកំណត់

៥— មិនមែនជាអ្នកមានសេចក្តីប្រាថ្នាដើម្បីចេញចាកអាបត្តិ ៗ

ភិក្ខុដែលហាមមិនឱ្យធ្វើឧបោសថបវារណាគឺ=

ក) ជាអ្នកប្រកបដោយអង្គ ៥ យ៉ាងគឺ=

១— ជាអលជ្ជី

២– ជាមនុស្សពាល

៣– មនមែនជាបកគត្ត:

៤– ជាអ្នកមានសេចក្តីប្រាថ្នាលាភមក

៥– មិនមែនជាអ្នកមានសេចក្តីប្រាថ្នាដើម្បីចេញចាកអាបត្តិ ។

ខ) ជាអ្នកប្រកបដោយអង្គ ៥ យ៉ាងគឺ=

១– ជាអ្នកមានសេចក្តីប្រព្រឹត្តិដោយកាយមិនបរិសុទ្ធ

២– ជាអ្នកមានសេចក្តីប្រព្រឹត្តិដោយវាចាមិនបរិសុទ្ធ

៣– ជាអ្នកមានអាជីវមិនបរិសុទ្ធ

៤– ជាមនុស្សល្ងង់មិនឆ្លាត

៥– ជាអ្នកធ្វើការឈ្លោះនឹងវិវាទជានិច្ច ។

ភិក្ខុគួរពិចារណាមានលក្ខណៈដូច្នេះគឺ=

១–ជាអ្នកមានសីល ជាពហុស្សុត ជាអ្នកទ្រទ្រង់បាតិមោក្ខ ជាអ្នកអាចកាត់សេចក្តីឲ្យគូក្តីចូលចិត្តនិងជ្រះថ្លា ។

២–ជាអ្នកមានកាយសមាចារបរិសុទ្ធ ជាអ្នកមានវចីសមាចារបរិសុទ្ធ ជាអ្នកមានអាជីវបរិសុទ្ធ ជាបណ្ឌិតឆ្លាត អាចដើម្បីឆ្លើយនូវដែលសួរត្រូវ ។

៣– ចេះវត្ថុ ចេះនិទាន ចេះព្រះបញ្ញត្តិ ចេះបទជាខាងក្រោយ ស្គាល់បំណងនៃពាក្យ ដែលចូលអនុសន្ធិដល់គ្នានិងគ្នា ។

៤– ចេះធម៌ ចេះវិន័យ តាំងអនុលោម ជាអ្នកឆ្លាតក្នុងឋានៈនិងអឋានៈគឺហេតុដែលអាចកើតបាន និងហេតុដែលមិនអាចកើតបា ជាអ្នកឆ្លាតក្នុងអត្ថនិងព្យញ្ជនៈ ជាខាងដើមនិងខាងចុង សមគ្នាឬមិនសម ជាអ្នកឆ្លាតក្នុងវិនិច្ឆ័យ ។

## ភិក្ខុអ្នកពិចារណាក្តីគប្បីតាំងខ្លួនដូច្នេះគឺ=

១– ជាអ្នកធ្ងន់ក្នុងសង្ឃ មិនគប្បីធ្ងន់ចំពោះបុគ្គល

២– ជាអ្នកធ្ងន់ក្នុងសទ្ធម្ម មិនគប្បីធ្ងន់ក្នុងអាមិស

៣– គប្បីជាអ្នកប្រព្រឹត្តទៅតាមអំណាចនៃក្តី មិនគប្បីយល់ដល់បរិស័ទ

៤– គប្បីស្គាល់ទីអង្គុយ

៥– គប្បីអង្គុយអាសនរបស់ខ្លួន ដាក់ភ្នែកសំយុងចុះមួយរយៈនឹម ហើយពិចារណាសេចក្តី ។

៦– មិនគប្បីក្រោកចាកអាសនៈ ទៅណាមកណាក្នុងពេលនោះ

៧– មិនគប្បីសេពគប់ផ្លូវខុស

៨– មិនគប្បីនិយាយឆ្កាដៃឆ្កាជើង ក្នុងពេលជំរះក្តី

៩– មិនជាអ្នកនិយាយបណ្តោយ ជាអ្នកនិយាយមានទីបំផុត

១០– ជាអ្នកមិនរុករាន មិនឡេះឡោះ

១១– ជាអ្នកមិនចងពៀរ ជាអ្នកមិនខឹងងាយ

១២– ជាអ្នកមិនកោងកាច ជាអ្នកអត់ធន់

១៣– ជាអ្នកមានចិត្តមេត្តា ជាអ្នកគិតដល់ប្រយោជន៍

១៤– ជាអ្នកមានករុណា ខ្វល់ខ្វាយដើម្បីប្រយោជន៍

១៥– ជាអ្នកស្គាល់ឋានៈរបស់ខ្លួន

១៦– ជាអ្នកស្គាល់គុណរបស់អ្នកដទៃ

១៧– គប្បីសង្កេតអ្នកចោទ ថាជាមនុស្សដូចម្តេច

១៨– គប្បីសង្កេតអ្នកចម្លើយថាជាមនុស្សដូចម្តេច

១៩– ជាអ្នកមានស្មារតីតិចគប្បីនិយាយលួងលោម

២០– ជាអ្នកខ្លាច គប្បីនិយាយដោយពាក្យប្រលោម

២១– បើជាមនុស្សកាចគប្បីនិយាយហាមឃាត់

២២– ជាអ្នកមានសេចក្តីប្រព្រឹត្តមិនស្អាតគប្បីខ្ញូន្ទាន

២៣ បើជាអ្នកស្លូតត្រង់គប្បីធ្វើដោយសេចក្តីលំឱនលំទន

២៤- មិនគួរធ្វើដោយឆន្ទាគតិ

២៥ – មិនគួរធ្វើដោយទោសាគតិ

២៦ – មិនគួរធ្វើដោយមោហាគតិ

២៧ – មិនគួរធ្វើដោយភយាគតិ

២៨ – គប្បីដាក់ខ្លួនជាកណ្ដាល ចំពោះធម៌និងបុគ្គល

២៩ – គប្បីសួរដោយកាល មិនគប្បីសួរខុសកាល

៣០ – សួរដោយពាក្យពិត មិនសួរពាក្យកុហក

ខ ដែលហាមមិនឱយសួរគឺ=

ក) មិនឲ្យសួរដល់ឧបជ្ឈាយ៍

ខ) មិនឲ្យសួរដល់អាចារ្យ

ឃ) មិនឲ្យសួរដល់អន្តេវាសិក

ង) មិនឲ្យសួរដល់ភិក្ខុរួមឧបជ្ឈាយ៍ជាមួយគ្នា

គ) មិនឲ្យសួរដល់សទ្ធិវិហារិក

ច) មិនឲ្យសួរដល់ភិក្ខុរួមអាចារ្យជាមួយគ្នា

ឆ) មិនឲ្យសួរដល់ជាតិ ឈ្មោះ គោត្រ អាគម មាតុភូមិ ។

ការដែលហាមដូច្នេះនេះ ដើម្បីការពារមិនឲ្យមានសេចក្ដីស្រឡាញ់ឬស្អប់

ដែលជាហេតុដល់នូវអាគតិទាំង ៤ ។

## កណ្ឌទី ៣០

## អាបត្តាធិករណ៍

អាបត្តិទាំងអស់ដែលភិក្ខុត្រូវហើយ ត្រូវតែសំដែងឬប្រព្រឹត្ត ដើម្បីសេចក្តីបរិសុទ្ធិ ចាត់ជាអធិករណ៍មួយ រម្ងាប់ក្នុងសំណាក់បុគ្គលក៏មាន ក្នុងសំណាក់សង្ឃក៏មាន ។

### អាបត្តិមាន ២ យ៉ាងគឺ=

១- លហុកាបត្តិ អាបត្តិស្រាលរម្ងាប់ក្នុងសំណាក់បុគ្គល

២- គរុកាបត្តិ អាបត្តិធ្ងន់ត្រូវរម្ងាប់ក្នុងសំណាក់សង្ឃ ។

### អាបត្តាធិករណ៍ត្រូវរម្ងាប់ដោយសមថ ២ យ៉ាងគឺ

១- សម្មុខាវិន័យ នាំទៅចំពោះមុខ

២- បដិញ្ញាតករណៈ ធ្វើតាមទទួលសារភាព ។

ចម្លើយគប្បីមានសមណសញ្ញា នឹងគប្បីខ្លាចក្រែងនូវអាជ្ញាសង្ឃ ឲ្យការដោយត្រង់ ។ កុំកែខ្លួនដោយពាក្យភរកុហក ។

### វិធីរម្ងាប់គរុកាបត្តិ

ភិក្ខុត្រូវគរុកាបត្តិ ត្រូវប្រព្រឹត្តមានត្ត ៦ រាត្រី រួចសង្ឃសូត្ររម្ងាប់អាបត្តិហៅថាអព្ភាន តែបើបិទបាំងអាបត្តិ ដែលត្រូវនោះអស់ប៉ុន្មានថ្ងៃ ត្រូវប្រព្រឹត្តវត្តហៅថាចូលបរិវាស ឲ្យគ្រប់ថ្ងៃដែលបិទបាំងនោះ រួចហើយទើបប្រព្រឹត្តមានត្តតទៅ ។ ក្នុងពេលដែលកំពុងចូលបរិវាសនោះ ដំរាបណាដែលសង្ឃមិនទាន់ឲ្យអព្ភាន ត្រូវគរុកាបត្តិដូច្នោះ ឬទៃទៀតក្តី ត្រូវត្រឡប់ចូលបរិវាសឬប្រព្រឹត្តមានត្តជាថ្មីទៀត ហៅថាបដិកស្សនា ប្រែថាកិរិយាត្រឡប់រកអាបត្តិដើម ។ បរិវាស មានត្ត បដិកស្សនា អព្ភាន ទាំង ៤ នេះរួមហៅថាវុដ្ឋានវិធី ប្រែថា វិធីចេញចាកអាបត្តិ ។

## សង្ឃអ្នកធ្វើកម្មទាំងនេះមាន ២ ពួកគឺ=

១– សង្ឃចតុវគ្គ បួនរូប ឲ្យបរិវាស មានត្ត និងបដិកស្សនា,

២– សង្ឃវីសតិវគ្គ ម្ភៃរូប ឲ្យអព្ភាន

តែលោកហាមមិនឲ្យយកភិក្ខុដែលកំពុងប្រព្រឹត្ត វុដ្ឋានវិធី ចូលជាមួយគំរប់ផង គឺជាទី ៤ នៃសង្ឃចតុវគ្គ និងជាទី ២០ នៃសង្ឃវីសតិវគ្គ ។

## វុដ្ឋានវិធីមាន ៣ យ៉ាងគឺ=

១– សំរាប់អាបត្តិ ដែលមិនបានបិទបាំង

២– សំរាប់អាបត្តិ ដែលបិទបាំងទុក

៣—សំរាប់អាបត្តិ ដែលត្រូវក្នុងរវាងដែលកំពុងប្រព្រឹត្តវត្ត ។

## វុដ្ឋានវិធីសំរាប់អាបត្តិ ដែលមិនបានបិទបាំងដូច្នេះគឺ=

ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ គប្បីធ្វើសំពត់ឆៀងស្មាម្ខាង ចូលទៅរកគ្រាប់បាទភិក្ខុដែលចាស់វស្សាជាង រួចហើយអង្គុយប្រហោង ប្រណម្យអញ្ជលីពោលពាក្យសុំមានត្តដោយសមគួរ ដល់អាបត្តិដែលត្រូវ ក្នុងលំដាប់នោះភិក្ខុដែលឆ្លាតគប្បីសូត្រប្រកាសសង្ឃ ដើម្បីឲ្យមានត្ត ដល់ភិក្ខុនោះ ដោយញត្តិចតុត្ថកម្មវាចា លុះចប់អនុសាវនាទី ៣ ហើយ មានត្តឈ្មោះថាសង្ឃបានឲ្យហើយភិក្ខុនោះឈ្មោះថា មានត្តចារិកោ ប្រែថា អ្នកប្រព្រឹត្តមានត្ត ផុតចាកការជាប់គត់ហើយ, ភិក្ខុអ្នកប្រព្រឹត្ត មានត្តត្រូវឲ្យគ្រប់៦រាត្រី បើមានហេតុនឹងសំរាក ក្នុងពេលដែលចូល នោះក៏បាន ហៅថាដាក់វត្ត និងរាប់រាត្រីផងពុំបានឡើយ

## វិធីដាក់វត្តនិងសមាទានវត្ត

គប្បីធ្វើសំពត់ឆៀងស្មាម្ខាង ចូលទៅរកភិក្ខុមួយរូបអង្គុយប្រហោង ប្រណម្យអញ្ជលី ពោលនូវពាក្យដាក់និងសមាទានថាដូច្នេះ៖

## ពាក្យដាក់វត្តនិងមានត្តថា

វត្តំ និក្ខិបាមិ មានត្តំ និក្ខិបាមិ, (១) ប្រែថា ខ្ញុំម្ចាស់ដាក់វត្ត

១)ទុតិយម្បិ - - - , តតិយម្បិ - - - ។

ខ្ញុំម្ចាស់ដាក់មានត្ត ។

## ពាក្យសមាទានវត្តនិងមានត្តថា

មានត្តំ សមាទិយាមិ វត្តំ សមាទិយាមិ, (១) ប្រែថា ខ្ញុំម្ចាស់សមាទានមានត្ត ខ្ញុំម្ចាស់សមាទានវត្ត ។

## រត្តិច្ឆេទ ដាច់រាត្រីមាន ៤ យ៉ាងគឺ=

១–សហវាសោ នៅរួមសំយាបកុដិជាមួយនឹងបកតត្តភិក្ខុ

២–វិប្បវាសោ នៅក្នុងអាវាសដែលប្រាសចាកសង្ឃ

៣–អនារោចនា មិនប្រាប់ការដែលខ្លួនប្រព្រឹត្តមានត្ត

៤–ឩនគណេចរណំ ប្រព្រឹត្តក្នុងគណៈខ្វះខាត ។

មិនឲ្យមានត្តចារិកភិក្ខុត្រេកអរទទួលកិច្ចការ របស់បកតត្តភិក្ខុ ១០ យ៉ាងគឺៈ

១–មិនឲ្យត្រេកអរដោយកិច្ចអភិវាទនកម្ម

២– „ „ការក្រោកទទួល

៣– „ „អញ្ជលិកម្ម

៤– „ „សាមីចិកម្ម

៥–មិនឲ្យត្រេកអរនឹងការនាំអាសនៈមកឲ្យ

១) ទុតិយម្បិ . . ., តតិយម្បិ . . . ។

៦— មិនឲ្យត្រេកអរដោយការនាំទីដេកមកឲ្យ

៧— មិនឲ្យត្រេកអរដោយការលាងជើង

៨— មិនឲ្យត្រេកអរដោយការតាំងកំណល់គល់ជើង

៩— មិនឲ្យត្រេកអរដោយការតាំងកំពលជូតជើង

១០— មិនឲ្យត្រេកអរដោយ ចូលទទួលបាត្រនឹងចីវរ ។

បើមានត្តចារិកភិក្ខុ ល្មើសខហាមនេះត្រូវអាបត្តិទុក្កដ, តែទ្រង់អនុញ្ញាតឲ្យមានត្តចារិកភិក្ខុ ធ្វើកិច្ចទាំងនោះជាគូគ្នាបាន តាមវស្សាចាស់និងខ្ចី ។

ខដែលទ្រង់អនុញ្ញាត

## ឱយមានត្តចារិកភិក្ខុ ធ្វើតាមលំដាប់វស្សា ៥ យ៉ាងគឺ=

១— ការធ្វើឧបោសថ

២— ការបវារណា

៣— ការទទួលវស្សិកសាដក

៤— ការលះកគ្គ

៥— ការទទួលកគ្គ ។

## វត្តរបស់មានត្តចារិកភិក្ខុ ១០ ពួកគឺ=

១—មិនគប្បីឲ្យឧបសម្បទទិងនិស្ស័យ មិនគប្បីមានសាមណេរឧបដ្ឋាក មិនគប្បីទទួលសន្មតជាអ្នកប្រដៅភិក្ខុនី,

២ – សង្ឃឲ្យមានត្តដើម្បីអាបត្តិណា មិនគប្បីត្រូវអាបត្តិនោះឬអាបត្តិដទៃដូចគ្នា ឬ អាបត្តិធ្ងន់ជាងនោះ,

៣—មិនគប្បីតិះដៀលកម្មនោះ ទិងភិក្ខុដែលធ្វើកម្មនោះ មិនគប្បីហាមឃាត់ឧបោសថ បវារណាដល់បកតត្តភិក្ខុ មិនគប្បីធ្វើសេចក្តីយល់ឃើញមិនគប្បីផ្តើមអនុវាទាធិករណ៍ មិនគប្បីញ៉ាំងភិក្ខុដទៃ ដើម្បីឧកាសចោទគេ មិនគប្បីចោទភិក្ខុដទៃ មិនគប្បីជួយភិក្ខុទាំងឡាយ ឲ្យតក្កីក្នុងអធិករណ៍,

៣– មិនគប្បីទៅមុនអង្គុយខាងមុខ នៃបកតត្តភិក្ខុ គប្បីពេញចិត្តនឹងអាសនៈទីដេកកុដិជាខាងចុងបំផុតនៃសង្ឃ ។

៤– មិនគប្បីមានបកតត្តភិក្ខុ ដើរមុខឬតាមក្រោយ ចូលទៅកាន់ត្រកូល មិនគប្បីសមាទានអរញ្ញិកទិងបិណ្ឌបាតិកធុតង្គ មិនគប្បីឲ្យគេនាំបិណ្ឌបាតមកជូន ព្រោះបច្ច័យនោះដោយគិតថា កុំឲ្យគេដឹងកិច្ចរបស់យើង,

៦– បើជាអាគន្តុកទៅកាន់ដទៃ គប្បីប្រាប់ការដែលខ្លួនប្រព្រឹត្តមានត្ត

ត្តបើមានអាគន្តុកមកក៏គប្បីប្រាប់ គប្បីប្រាប់ក្នុងឧបោសថ ក្នុងបវារណា គប្បីប្រាប់កាលថ្ងៃ បើអាពាធគប្បីប្រើទូតឲ្យទៅប្រាប់

៧— គប្បីចេញចាកអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលមិនមានភិក្ខុ ឬមានតែនានាសំវាស វៀរលែងតែទៅជាមួយសង្ឃ ឬមានអន្តរាយ គប្បីទៅកាន់តែអាវាសណាដែលមានភិក្ខុជាសមានសំវាស ឬអាចដឹងថាទៅដល់ក្នុងថ្ងៃនោះ ។

៨— មិនគប្បីនៅក្នុងទីប្រកទីបាំង ជាមួយនឹងបកតត្តភិក្ខុ

៩— បើឃើញបកតត្តភិក្ខុហើយ ត្រូវក្រោកចាកអាសនចេញហើយនិមន្តបកតត្តភិក្ខុគង់ បើលោកគង់អាសនទាប យើងមិនគួរអង្គុយអាសនខ្ពស់ បើលោកគង់នៅទីដី យើងមិនអង្គុយលើអាសនមិនគប្បីចង្រ្កមណ៍ក្នុងកន្លែងជាមួយគ្នា បើលោកចង្រ្កមណ៍នៅកន្លែងទាប យើងមិនគប្បីចង្រ្កមណ៍ ក្នុងទីចង្រ្កមណ៍ ។

១០— មិនគប្បីនៅក្នុងទីប្រក់ជាមួយគ្នា ក្នុងអាវាសក្តី ក្នុងកន្លែងមិនមែនអាវាសក្តី នឹងភិក្ខុដែលចូលបរិវាស នឹងភិក្ខុដែលគួរត្រឡប់កែអាបត្តិដើម នឹងភិក្ខុដែលគួរមានត្ត នឹងភិក្ខុដែលប្រព្រឹត្តមានត្តតាសជាង នឹងភិក្ខុដែលគួរអព្ភាន ។

## សេចក្ដីបំណងនៃការបញ្ញត្តិវត្ត ៣០យ៉ាងគឺ=

ពួកទី ១ ដោយសេចក្ដីគឺហាមមិនឲ្យធ្វើការក្នុងនាទីរបស់ព្រះថេរៈ

" ២– ដោយសេចក្ដីគឺប្រុងឲ្យនៅក្នុងសេចក្ដីប្រយ័ត្ន

" ៣– ដោយសេចក្ដីគឺហាមមិនឲ្យប្រកាន់សិទ្ធិនៃបកតត្ត

" ៤– ដោយសេចក្ដីគឺហាមសិទ្ធិដែលនឹងគប្បីកាន់យកតាមលំ-ដាប់វស្សា

" ៥– ដោយសេចក្ដីគឺហាមមិនឲ្យប្រហែសធ្វេសខ្លួន ដើម្បីឲ្យមានការប្រយ័ត្នជានិច្ច

" ៦– ដោយសេចក្ដីគឺឲ្យអ្នកដទៃដើម្បីផ្ចាញ់ផ្ចាលខ្លួន

" ៧– ដោយសេចក្ដីគឺហាមវិប្បវាស គឺការប្រាសចាកសង្ឃ

" ៨– ដោយសេចក្ដីគឺហាមការសម្ភោគ នឹងបកតត្ត

" ៩– ដោយសេចក្ដីគឺឲ្យសំដែងសាមីចិកម្ម ដល់បកតត្តភិក្ខុក៏មានហាមសម្ភោគក៏មាន ។

" ១០– ដោយសេចក្ដីហាមសម្ភោគនឹងភិក្ខុដែលកំពុងចូលវុដ្ឋានវិធីដូចគ្នា ។

លុះប្រព្រឹត្តមានវត្តគ្រប់តាមកំណត់ហើយ ជាអ្នកគួរដល់អព្ភាន ក៏

គប្បីសុំអព្ភានក្នុងសំណាក់សង្ឃវីសតិវគ្គ លុះអព្ភានរួចហើយ ឈ្មោះថាជាអ្នកចេញចាកគរុកាបត្តិ ទើបបានជាបកតត្តដូចដើមវិញ ។

## វុដ្ឋានវិធីសំរាប់អាបត្តិដែលបិទបាំងដូច្នេះគឺ=

១– ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ តាំងចិត្តបិទបាំងទុកអស់ប៉ុន្មានគប្បីចូលបរិវាសអស់ថ្ងៃប៉ុណ្ណោះ ហើយគប្បីសុំមានត្តតាមរបៀប ជាអ្នកមានមានត្តប្រព្រឹត្តរួចហើយ ក៏គប្បីសុំអព្ភានចំពោះសង្ឃ ។

## លក្ខណបិទបាំងអាបត្តិចាត់ជាគូមាន ៥ គឺ=

១– ជាអាបត្តិហើយដឹងថាជាអាបត្តិ

២– ជាបកតត្ត ដឹងថាជាបកតត្ត

៣– មិនមានអន្តរាយ ហើយដឹងថាមិនមានអន្តរាយ

៤– អាចដើម្បីទៅប្រាប់បានហើយដឹងថាអាច ដើម្បីទៅប្រាប់បាន

៥– ប្រាថ្នានឹងបិទ ហើយបិទទុក ។

## បរិវាសមាន ៣ យ៉ាងគឺ=

១–បដិច្ឆន្នបរិវាស

២– សមោធានបរិវាស

៣– សុទ្ធន្តបរិវាស

បដិច្ឆន្នបរិវាស សម្រាប់អាបត្តិដែលបិទមានកំណត់កល់ថ្ងៃដែលបិទបាន ចំនួនប៉ុន្មានថ្ងៃ ក៏ចូលទៅតាមចំនួនថ្ងៃនោះ សូម្បីថ្ងៃនោះតិចជាង១៥ថ្ងៃ ឬតិចជាង១ខែ ក៏រាប់ពេញ១៥ថ្ងៃ ឬពេញ១ខែ ។

## សមោធានបរិវាសចែកចេញជា ៣ យ៉ាងគឺ=

១– ឱធានសមោធាន សម្រាប់អាបត្តិដែលត្រូវច្រើនជង តែមានថ្ងៃបិទស្មើគ្នា គប្បីសូមប្រមូលអាបត្តិនិងរាត្រីចូលគ្នាបាន ។

២– អគ្ឃសមោធាន សម្រាប់អាបត្តិដែលមានថ្ងៃបិទមិនស្មើគ្នា គប្បីសូមបរិវាសប្រមូលអាបត្តិនិងថ្ងៃចូលគ្នា ហើយចូលបរិវាសទៅតាមចំនួនថ្ងៃដែលច្រើនជាង ។

៣– មិស្សកសមោធាន សម្រាប់អាបត្តិមានវត្ថុផ្សេងគ្នា ដូចជា សក្កោតទិកា កាយសំសគ្គ ទុដ្ឋុល្លវាចា មានថ្ងៃបិទស្មើគ្នាក៏មាន មិនស្មើគ្នាក៏មាន ។

## សុទ្ធន្តបរិវាសចែកចេញជា ២ យ៉ាងគឺ=

១– ចូឡសុទ្ធន្តបរិវាស សម្រាប់ចំនួនអាបត្តិនិងរាត្រីដែលល្មមចាំបាន ។

២– មហាសុទ្ធន្តបរិវាស សម្រាប់ចំនួនអាបត្តិនិងរាត្រីដែលចាំមិន

បានសោះ ។

ការតាំងចំនួនអាបត្តិមិនបាន អាចប្រមូលចូលជា សម្ពហលា បើតាំងរាត្រីមិនបាន គប្បីកំណត់ថា តាំងតែពីឧបសម្បទមក ចំនួនប៉ុន្មានថ្ងៃ ដែលមិនត្រូវតែត្រូវអាបត្តិនោះ នេះជាការស្មានយកខាងដើម ថយក្រោយចូលទៅត្រឹមណាដែលមិនត្រូវសោះនោះ នេះជាការស្មានយកខាងចុង គប្បីចូលបរិវាសក្នុងវេងកណ្ដាល ។

បរិវាសកិច្ចនេះ គប្បីប្រាប់ដល់សង្ឃ ដល់ការដែលខ្លួនប្រព្រឹត្ត-បរិវាសនោះ បើនឹងមិននៅក្នុងបរិវាសនោះគប្បីដាក់បរិវាស ក្នុងកំណត់នៃភិក្ខុមួយរូប ទៅដល់អាវាសដែលខ្លួននឹងនៅ ក៏គប្បីសមាទានបរិវាស - តាមវិធីដែលប្រើក្នុងអដ្ឋកថាន័យ សមាទានបរិវាសចំពោះមុខសង្ឃហើយ ទើបប្រាប់ ។ ហើយទើបដាក់បរិវាស ។

## ពាក្យដាក់បរិវាស

វត្តំ និក្ខិបាមិ បរិវាសំ និក្ខិបាមិ (១) ប្រែថា ខ្ញុំម្ចាស់ដាក់វត្ត ខ្ញុំម្ចាស់ដាក់បរិវាស ។

## ពាក្យសមាទានថា

បរិវាសំ សមាទិយាមិ, វត្តំ សមាទិយាមិ(២) ប្រែថា ខ្ញុំម្ចាស់

១) ទុតិយម្បិ...តតិយម្បិ .... ។ ២)ទុតិយម្បិ... តតិយម្បិ.,. ។

សមាទានបរិវាស ខ្ញុំម្ចាស់សមាទានវត្ត ។

## រត្តិឆេទនៃបារីវាសភិក្ខុមាន ៣ យ៉ាគឺ=

១–សហវាសោ នៅរួម

២–វិប្បវាសោ នៅប្រាសចាក

៣–អនារោចនា មិនប្រាប់ការ ។

សហវាស ដូចរបស់មានត្តចារិកភិក្ខុ ; វិប្បវាសក៏ដូចគ្នា ។ ប្លែកតែក្នុងទីនេះមានបកតត្តមួយរូបនៅជាមួយគ្នាក៏បាន ។ អនារោចនា មិនត្រូវ-ប្រាប់ រាល់ថ្ងៃ ប្រាប់រួចម្តងហើយមិនត្រូវប្រាប់ទៀត រហូតកាលដែលនៅក្នុងអាវាស ឬទីដែលមិនមែនជាអាវាសានោះ តែប្រសិនបើភិក្ខុដែលប្រាប់ហើយនោះចេញទៅអំពីទីដែលនៅទៅ ត្រឡប់មកវិញត្រូវប្រាប់-ភិក្ខុនោះជាថ្មីទៀត ។

ដល់ថ្ងៃឧបោសថបវារណា គប្បីប្រាប់នៅទីបំផុតនៃឧបោសថបវារ-ណានោះគ្រប់ពេលជានិច្ច ។ ព្រះពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងវត្តសំរាប់បារីវាសិកភិក្ខុនេះក៏ដូចគ្នា និងមានត្តចារិកភិក្ខុនោះដែរ វៀរលែងតែប្រាប់ និងទៅកាន់ទីដទៃ ដូចដែលពោលមកហើយ ។

## ការសុំបរិវាសបន្ថែមថ្ងៃដូច្នេះ

ដូចជាភិក្ខុសុំអត្ថសមោធាន សំគាល់ថាអាបត្តិដែលបិទយូរបំផុត ៧ថ្ងៃ បានសូមចំពោះសង្ឃហើយ កាលដែលកំពុងចូលបរិវាសនោះនឹកឃើញថា អាបត្តិដែលបិទទុកយូរបំផុត ១០ថ្ងៃ ដូច្នេះនេះមិនបាច់សុំបរិ-វាសសាដើម ជាថ្មីទៀតទេ គឺសូមបន្ថែមទៀត៣ថ្ងៃ នឹងមិនបន្ថែមយកដោយខ្លួនឯងត្រូវសូមសង្ឃឲ្យសង្ឃសូត្របន្ថែមឲ្យ ។

## វុដ្ឋានវិធីសំរាប់អន្តរាបត្តិមាន ៤ យ៉ាងគឺ=

១– បើត្រូវអន្តរាបត្តិ មិនបានបិទទុក ក្នុងវេលាដែលកំពុងប្រព្រឹត្តមានត្តឬប្រព្រឹត្តហើយ គប្បីសូមបដិកស្សនា ស្រេចហើយទើបសូមមានត្តដើម្បីអន្តរាបត្តិ ។

២– បើត្រូវអាបត្តិមិនបានបិទទុក ក្នុងវេលាដែលកំពុងចូលបរិវាសឬចូលរួចហើយ គប្បីសូមបដិស្សនារួចហើយចូលបរិវាសសាដើមជាថ្មី ស្រេចហើយទើបសូមមានត្ត ដើម្បីអាបត្តិដើមនិងអន្តរាបត្តិប្រមូលគ្នា ។

៣– បើត្រូវអន្តរាបត្តិមិនបានបិទទុក ក្នុងវេលាដែលកំពុងចូលបរិវាសឬចូលហើយ កំពុងតែប្រព្រឹត្តមានត្តនៅ ជាអព្ភារហ គប្បីសូមបដិកស្សនា លុះសូមរួចហើយ គប្បីសូមមានត្តដើម្បីអន្តរាបត្តិ មិន

បាច់ចូលបរិវាសទៀតទេ ។

៤– បើត្រូវអន្តរាបត្តិហើយបិទទុក ក្នុងវេលាកំពុងចូលបរិវាស ឬចូលរួចហើយ សូម្បីត្រូវអាបត្តិក្នុងវេលាកំពុងប្រព្រឹត្តមានត្ត ឬប្រព្រឹត្តរួចហើយ ក៏គប្បីសូមបដិកស្សនា លុះរួចហើយ គប្បីសូមសមោធានបរិវាស ដើម្បីប្រមូលអន្តរាបត្តិ ចូលនឹងអាបត្តដើម ។

ភិក្ខុមួយរូបគប្បីសូត្រប្រកាសសង្ឃ ដោយញត្តិចតុត្ថកម្មវាចា ទាញភិក្ខុនោះ ចូលទៅរកអាបត្តិដើមវិញ ឲ្យបរិវាសនិងមានត្តដល់ភិក្ខុនោះ តាមរឿងរ៉ាវដែលសុំ ព្រមទាំងអព្ភានឲ្យផង លុះគ្រាភិក្ខុនោះប្រព្រឹត្តមានត្តរួចហើយ សង្ឃបានអព្ភានឲ្យហើយ ភិក្ខុនោះក៏ត្រឡប់ជាបកតត្តភិក្ខុតាមដើម ។

## អ្នកដែលគួរប្រព្រឹត្តជាថ្មីទៀតនោះគឺ=

ក) ភិក្ខុប្រព្រឹត្តវុដ្ឋានវិធី ហើយបានប្តេជ្ញាខ្លួនជាអនុបសម្បន្ន លុះដល់ឧបសម្បទថ្មី ត្រូវប្រព្រឹត្តទៅទៀតឲ្យគ្រប់តាមចំនួនថ្ងៃដែលនៅសល់ ។

ខ) ភិក្ខុត្រូវគរុកាបត្តិហើយ នៅមិនទាន់បានចេញចាកអាបត្តិនោះ សឹកចេញទៅ លុះឧបសម្បទមកវិញកាលណា ត្រូវប្រព្រឹត្ត

វុដ្ឋានវិធី ។

គ) ភិក្ខុឆ្កួត ភិក្ខុអាពាធខ្លាំង ឬ រសាប់រសល់ដល់មិនមានសតិសម្បជញ្ញៈ និងភិក្ខុដែលត្រូវជាកឧក្ខេបនីយកម្ម ក៏ដូចគ្នាដែរ, ភិក្ខុត្រូវអា-បត្តិហើយ ប្រព្រឹត្តវុដ្ឋានវិធីតាំងពីខាងដើមរហូតដល់អព្ភាន ឈ្មោះថា ចេញចាកអាបត្តិហើយ ទើបត្រឡប់មកជាបកតត្តវិញដូចដើម ។ យ៉ាងនេះអាបត្តាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈ ។

សម្មុខាវិន័យក្នុងទីនេះប្រកបព្រមដោយអង្គ ៤ គឺ=

១– សង្ឃសម្មុខតា

២– ធម្មសម្មុខតា

៣– វិនយសម្មុខតា

៤– បុគ្គលសម្មុខតា ។

វិធីរម្ងាប់លហុកាបត្តិដោយតិណវត្ថារកវិន័យដូច្នេះគឺ=

ភិក្ខុទាំងឡាយគប្បីប្រជុំក្នុងកន្លែងមួយជាមួយគ្នាទាំងអស់ ភិក្ខុមួយរូបដែលឆ្លាត គប្បីសូត្រប្រកាសសង្ឃដោយញត្តិកម្ម ក្នុងលំដាប់នោះ ភិក្ខុមួយរូបក្នុងបក្ខមួយនោះ គប្បីប្រកាសដោយគណញត្តិ សូមអនុម័តិ

ដើម្បីជាអ្នកសំដែងអាបត្តិ ជំនួសគណៈរបស់ខ្លួននិងខ្លួនឯងផង មួយបក្សទៀតក៏ធ្វើដូចគ្នាយ៉ាងនោះដែរ ទាំងពីរបក្សគប្បីសូត្រប្រកាសសន្មតដូចគ្នា ដោយញត្តិទុតិយកម្មវាចា សំដែងអាបត្តិជំនួសបក្សរបស់ខ្លួនៗនិងខ្លួនឯងផង ក្នុងទីប្រជុំសង្ឃ ដោយតិណវត្ថារកវិធី ។

ធ្វើដោយវិធីនេះភិក្ខុទាំងឡាយ នោះឈ្មោះថាផុតចាកអាបត្តិហើយ វៀរលែងតែអាបត្តិមានទោសហួសខែត្រ និងអាបត្តិដែលទាក់ទងដោយគ្រហស្ថ វៀរលែងតែអ្នកសំដែងនូវសេចក្តីយល់ទាស់ វៀរលែងតែអ្នកដែលមិនបាននៅក្នុងទីនោះ ។

## អាបត្តិដែលផុតទៅមិនបានគឺ

១– អាបត្តិដែលមានទោសហួសខេត្ត បានដល់អាបត្តិបារាជិកនិងសង្ឃាទិសេស ។

២– អាបត្តិដែលទាក់ទងដោយ គហស្ថនោះ បានដល់ការជេរគ្រហស្ថហើយទទួលប្តេជ្ញា ត្រឹមត្រូវតាមធម៌ របស់គេហើយ ធ្វើឲ្យភ្លាំងភ្លាត់ដែលហៅថាបដិស្សវ ។

## អាបត្តាធិករណ៍នេះរម្ងាប់ដោយសមថ ២ យ៉ាងគឺ=

១– សម្មុខាវិន័យ ក្នុងទីនេះព្រមដោយអង្គ ៤ ថែមបុគ្គលសម្មុខាតា

២– គណៈវត្តាគវិន័យ បានដល់អ្នកសំដែងនិងអ្នកទទួលព្រម មុខគ្នា ។

## អាបត្តិដែលភិក្ខុត្រូវហើយ មិនព្រមធ្វើឱយបរិសុទ្ធជា ហេតុនៃសេចក្ដីវិនាស ២ យ៉ាងគឺ=

១– ជាហេតុខូចស័លសាមញ្ញតា

២– ជាហេតុបែកសាមគ្គី ។

## ហេតុនៃឧក្ខេបនីយកម្ម ២ យ៉ាងគឺ=

១– ព្រោះមិនព្រមទទួលថាត្រូវអាបត្តិ

២– ព្រោះមិនព្រមជំរះអាបត្តិនោះចេញ ។

## កណ្ឌទី ៣១

## កិច្ចាធិករណៈនិងវិធីរម្ងាប់

កិច្ចដែលធ្វើដោយការប្រជុំសង្ឃ មានធ្វើអបលោកនកម្ម, ញត្តិកម្ម ញត្តិទុតិយកម្ម និងញត្តិចតុត្ថកម្ម នោះរួមហៅថា កិច្ចាធិករណ៍ តាមមតិរបស់ព្រះគន្ធរចនាចារ្យ ។ ការនិគ្គហដល់ភិក្ខុខ្លះ ដល់គ្រហស្ថខ្លះហៅថា កិច្ចាធិករណ៍ ក៏គឺបានដល់ការជេកនិគ្គហនោះឯង ។

## ចំណែកលោកអ្នកមាននាទីគ្រប់គ្រងគណៈ គប្បីមានធម៌ ២ យ៉ាងគឺ=

១– និគ្គហ ការគំរាម

២– បគ្គាហ ការបញ្ចោសរសើរ ។

## និគ្គហទ្រង់អនុញ្ញាតឱ្យសង្ឃធ្វើកម្ម ៦ យ៉ាងគឺ=

១– តជ្ជនីយកម្ម ព្យួរទោស

២– និយសកម្ម ដកយស

៣– បព្វាជនីយកម្ម ការបណ្តេញចេញ

៤– បដិសារណីយកម្ម ការឲ្យត្រឡប់លើកសារភាព

៥– ឧក្ខេបនីយកម្ម ការលើកចេញពាកគណៈ

៦– តស្សបាបិយសិកាកម្ម ការបន្ថែមទោស ។

## ១– តជ្ជនីយកម្ម មានវិធីធ្វើដូច្នេះគឺ=

ក) ធ្វើចំពោះមុខភិក្ខុនោះ សួររួចហើយទើបធ្វើៗតាមពាក្យប្តេជ្ញា ។

ខ) ធ្វើព្រោះត្រូវអាបត្តិហើយអាបត្តិនោះជាទេសនាគាមិនីនូវមិនទាន់បានសម្តែង,

គ) ចោទមុនហើយទើបធ្វើ ឲ្យចម្លើយធ្វើឲ្យការរួចហើយទើបធ្វើ ពិន័យអាបត្តិហើយទើបធ្វើ ។

ឃ) ធ្វើដោយធម៌ ដែលសង្ឃព្រមព្រៀងគ្នាធ្វើ ។

គួរធ្វើតជ្ជនិយកម្មដល់ភិក្ខុដែលប្រកបព្រមដោយអង្គ ៣ គឺ=

១— ជាអ្នកធ្វើសេចក្ដីចាស់ទែង ជាអ្នកធ្វើការឈ្លោះវិវាទនោលោ អ៊ឹងកង បង្កអធិករណ៍ក្នុងសង្ឃជាអង្គមួយ, ជាពាលមិនឆ្លាត មានអាបត្តិច្រើន មារយាទមិនសមរម្យជាអង្គមួយ, ជាអ្នកច្រឡូកច្របល់ដោយគ្រហស្ថ កិរិយាមិនសមរម្យជាអង្គមួយ ។

២— ជាអ្នកមានសីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ ។

៣— ពោលពាក្យតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

វត្តសំរាប់ភិក្ខុដែលត្រូវដាក់ឧក្ខេបនិយកម្មគប្បីប្រព្រឹត្តនោះ គឺ=

១— មិនគប្បីឲ្យឧបសម្បទនិស្ស័យ មិនគប្បីមានសាមណេរឧបដ្ឋាក មិនគប្បីទទួលសន្មតិជាអ្នកប្រដៅភិក្ខុនី សូម្បីបានទទួលសន្មតិមកហើយក៏ត្រូវឈប់ ។

២— សង្ឃធ្វើតជ្ជនិយកម្ម ព្រោះអាបត្តិណា មិនគប្បីត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃដែលដូចគ្នា ឬក៏ថោកទាបជាងនោះ មិនគប្បីតិះ

ដៀលកម្មនោះ និងភិក្ខុទាំងឡាយអ្នកធ្វើកម្មនោះ ។

៣- មិនគប្បីហាមឃាត់ឧបោសថ បវារណា ដល់បកតត្តភិក្ខុ មិនគប្បីញុំាងភិក្ខុដទៃ ឲ្យធ្វើឱកាសដើម្បីចូទនិង:ចោទភិក្ខុនោះ មិនគប្បីធ្វើសេចក្ដីយល់ឃើញ មិនគប្បីផ្ដើមអនុវាទាធិករណ៍ មិនគប្បីចោទភិក្ខុដទៃ មិនគប្បីជួយភិក្ខុទាំងឡាយឲ្យតស៊ូក្ដីគ្នាក្នុងអធិករណ៍ណាមួយ ។

## វិធីរម្ងាប់ផ្ចេះគឺ=

ភិក្ខុនោះគប្បីចូលទៅរកសង្ឃ ធ្វើសម្ពត់ឧត្តរាសង្គឆៀងស្មាម្ខាង ក្រាបបាទាភិក្ខុចាស់ជាងមួយរូប អង្គុយច្រហោងប្រណមអញ្ជលី ពោលពាក្យសុំរម្ងាប់កម្មនោះបីដងក្នុងខណៈនោះ ភិក្ខុដែលឆ្លាតគប្បីប្រកាសសង្ឃបរិយាយសេចក្ដីនោះ និងការដែលសង្ឃរម្ងាប់កម្មនោះ ដោយញត្តិចតុត្ថកម្ម គ្រាន់តែប៉ុណ្ណេះនេះក៏ឈ្មោះថាសង្ឃរម្ងាប់កម្មនោះហើយ ភិក្ខុនោះផុតទោស ។ កម្មនេះសង្ឃបានធ្វើដល់បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុជាមុនដំបូង ភិក្ខុពីររូបនេះជាក្រុមឆព្វគ្គីយ៍ ។

## ២– និយសកម្ម

ភិក្ខុមានអាបត្តិច្រើន ច្របូកច្របល់ដោយគ្រហស្ថ ដោយការមិនសមគួរ សង្ឃគប្បីធ្វើនិគ្គហ គឺបង្ខំឲ្យកាន់និស្ស័យទៀត សូម្បីជា

មជ្ឈិមភិក្ខុ ឬថេរៈភិក្ខុហើយក៏ដោយ ត្រូវត្រឡប់កាន់យកនិស្ស័យក្នុងសំណាក់នៃភិក្ខុ ដែលមានវស្សាខ្ពីជាង ។

វិធីធ្វើ វិធីរម្ងាប់ វត្ត ដូចគ្នានឹងតជ្ជនីយកម្ម ។ កម្មនេះសង្ឃបានធ្វើដល់ សេយ្យសកភិក្ខុជាមុនដំបូង ។

## ៣- បព្វាជនីយកម្ម

ភិក្ខុប្រទុសក៉យត្រកូល ប្រព្រឹត្តលាមក មានដំណឹងល្បីល្បាញ សង្ឃបានឃើញហើយ គួរនិគ្គហធ្វើកម្មនេះដល់ភិក្ខុនោះ បណ្ដេញឲ្យចេញចាកអាវាស ។ វិធីធ្វើ វិធីរម្ងាប់ វត្ត ដូចតជ្ជនីយកម្ម ។

គ្រាន់តែបំពេញលក្ខណៈ ៤ ទៀតគឺ=

១- លេងកំផ្លែង ជាកិរិយាក្មេងអ្នកស្រុក

២- លេងអនាចារ

៣- បំផ្លាញព្រះបញ្ញត្តិ

៤- មិច្ឆាជីវៈ

កម្មនេះសង្ឃធ្វើដល់ អស្សជិតនិងបុនព្វសុកភិក្ខុជាមុនដំបូង ។

## ៤- បដិសារានីយកម្ម

កម្មនេះសង្ឃគប្បីធ្វើដល់ភិក្ខុសំដីអាក្រក់ ជេរគ្រហស្ថជាអ្នកជ្រះថ្លា

ក្នុងព្រះពុទ្ធសាសនា គប្បីបង្គំឲ្យទៅសុំខមាទោសគេ បើមិនអាចទៅ គប្បីសន្មតភិក្ខុជាអនុទូតឲ្យទៅជំនួស ជួយនិយាយជាកិច្ច ផ្ទាល់ខ្លួនឬក្នុងនាមរបស់សង្ឃ ទើបសុំខមាទោស ។

## លក្ខណៈហេតុដែលធ្វើកម្មចាត់ជា ២ ពួកមួយ ៗ មាន ៥ គឺ=

១– ខ្វល់ខ្វាយដើម្បីមិនមែនលាភ ដើម្បីមិនមែនប្រយោជន៍ ដើម្បីនៅមិនបានក្នុងគ្រហស្ថ ជេរស្តីបង្អាប់បន្តុះគេ ញុះញង់ឲ្យគេបែកគ្នា

២– និយាយតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដល់គ្រហស្ថ និយាយសង្កត់សង្កិនគេ លើកយករឿងកំប៉ាំងវែលជាធម៌របស់គេ មកនិយាយឲ្យខុសពាក្យសេចក្ដីពិត ។

វិធីធ្វើព្រមតាំងវិធីម្យ៉ាប់ ដូចគ្នានឹងតជ្ជនីយកម្ម ។ កម្មនេះសង្ឃបានធ្វើដល់ សុធម្មភិក្ខុ ដែលជេរដល់ ចិត្តគហបតី ជាដំបូង ។

## ៥– ឧក្ខេបនីយកម្ម

### គប្បីធ្វើដល់ភិក្ខុប្រកបដោយអង្គ ៣ ណាមួយគឺ=

១ –ជាអ្នកមិនឃើញដល់អាបត្តិ

២ –ជាអ្នកមិនព្រមសំដែងអាបត្តិ

៣– ជាអ្នកមានទិដ្ឋិលាមកមិនព្រមលះ ។

## វត្តសំរាប់ប្រព្រឹត្តមាន ៦ យ៉ាងគឺ=

១– ជួបតជ្ជនីយកម្ម

២– ជួបតជ្ជនីយកម្ម

៣– មិនគប្បីត្រេកអរដោយការក្រាបសំពះ ការឈរទទួលអញ្ជលិកម្មសាមីចិកម្ម ការនាំអាសនៈមកឲ្យការលាងជើងឲ្យ ការតាំងកំពលជូតជើងឲ្យ ការទទួលបាត្រចីវរ ការដុះខ្នងវេលាងូតទឹកនៃបកតត្តភិក្ខុ ។

៤– មិនគប្បីកំចាត់បកតត្តភិក្ខុ ដោយសីលវិបត្តិ អាចារវិបត្តិទិដ្ឋិវិបត្តិ អាជីវវិបត្តិ មិនគប្បីញុំាងភិក្ខុឲ្យបែកគ្នា ។

៥– មិនគប្បីស្លៀកពាក់ដូចគ្រហស្ថ មិនគប្បីស្លៀកពាក់ដូចតិរ្ថិយ៍មិនគប្បីសេពគប់តិរ្ថិយ៍ គប្បីសេពគប់ភិក្ខុ គប្បីសិក្សាសិក្ខានៃភិក្ខុ ។

៦– មិនគប្បីនៅក្នុងអាវាស មានគ្រឿងប្រក់ជាមួយនឹងបកតត្តភិក្ខុបើឃើញបកតត្តភិក្ខុមក ត្រូវក្រោកចាកអាសនៈ មិនគប្បីជេញបកតត្តភិក្ខុពីខាងក្នុងនិងខាងក្រៅនៃវិហារ ។

ក្រៅពីនេះជួបតជ្ជនីយកម្ម, កម្មនេះសង្ឃធ្វើដល់ព្រះឆន្នភិក្ខុ ព្រោះទោសមិនឃើញអាបត្តិ មិនព្រមធ្វើអាបត្តិនោះវិញ ធ្វើដល់អរិដ្ឋភិក្ខុព្រោះមិនព្រមលះទិដ្ឋិបាបជាគ្រាដំបូង ។

## ៦- តស្សបាបិយសិកាកម្ម

វិធីធ្វើដូចតជ្ជនីយកម្ម ខុសតែកម្មនេះសង្ឃគប្បីធ្វើដល់ចម្លើយ ដែលមានចំណង់ចង់បាំងសេចក្តីប្រព្រឹត្តិអាក្រក់របស់ខ្លួន ឲ្យការមិនជាទីពេញចិត្តសង្ឃ ដូច្នេះគឺ:

១- ឲ្យការត្រឡប់ទៅត្រឡប់មក

២- បដិសេធហើយត្រឡប់ប្ដេជ្ញា ៗ ហើយត្រឡប់បដិសេធ

៣- និយាយទ្បេះទ្បោះ ដើម្បីលាក់បំពួនរឿងដែលគេសួរ

៤- និយាយមុសាចំពោះមុខ ៗ

កម្មនេះសង្ឃបានធ្វើដល់ ឧបាលភិក្ខុជាគ្រាដំបូង ៗ

## ផ្ងាបាត្រនិងផ្កាប់បាត្រ

ទ្រង់អនុញ្ញាតឲ្យធ្វើនិគ្គហដល់គ្រហស្ថ ដែលប្រព្រឹត្តខុសចំពោះសង្ឃហៅថា ផ្កាប់បាត្រ ៗ

## អ្នកដែលគួរត្រូវផ្កាប់បាត្រនោះសំដៅយកគ្រហស្ថ

ដែលប្រកបដោយទោស៨ប្រការណានិមួយគឺ:

១- ខ្វល់ខ្វាយដើម្បីមិនមែនលាភនៃភិក្ខុទាំងឡាយ

២- ខ្វល់ខ្វាយដើម្បីមិនមែនប្រយោជន៍ដល់ភិក្ខុទាំងឡាយ ៗ

៣– ខ្វល់ខ្វាយដើម្បីនៅមិនបាននៃភិក្ខុទាំងឡាយ

៤– ជេរស្តីបណ្តុះបង្អាប់ភិក្ខុទាំងឡាយ

៥– ញុះញង់ភិក្ខុទាំងឡាយឲ្យបែកគ្នា

៦– ត្មះតិះដៀល ព្រះពុទ្ធ

៧– ត្មះតិះដៀលព្រះធម៌

៨– ត្មះតិះដៀលព្រះសង្ឃ ។

## វិធីផ្កាប់បាត្រ

សង្ឃគប្បីប្រជុំគ្នា ភិក្ខុមួយរូបប្រកាសសង្ឃ បរិយាយទោសរបស់គេនោះ ការផ្កាប់បាត្រត្រូវធ្វើដោយញត្តិទុតិយកម្មវាចា តាំងពីត្រឹមធ្វើនោះមក ហាមមិនឲ្យភិក្ខុចូលទៅសេពគប់ មិនឲ្យទទួលបិណ្ឌបាតមិនឲ្យទទួលនិមន្ត មិនឲ្យទទួលទេយ្យទានរបស់គេ កាលបើអ្នកត្រូវផ្កាប់បាត្រនោះដឹងថាខ្លួនមានទោស ក៏ត្រឡប់ប្រព្រឹត្តល្អវិញ សង្ឃគប្បីរម្ងាប់កម្មនោះចេញហៅថាផ្ងាបាត្រ ។

## វិធីផ្ងាបាត្រ

អ្នកដែលត្រូវផ្កាប់បាត្រនោះ គប្បីធ្វើសំពត់ឆៀងស្មាម្ខាងចូលទៅរកសង្ឃក្រាបបាទាភិក្ខុទាំងឡាយ អង្គុយច្រហោងផ្គងអញ្ជលី ពោល

ពាក្យសូមផ្ងាបាត្រភិក្ខុមួយរូបគប្បីប្រកាសសង្ឃ ដើម្បីផ្ងាបាត្រដោយញត្តិទុតិយកម្មវាចា ។

កម្មនេះសង្ឃធ្វើដល់ ចៅវឌ្ឍលិច្ឆវី ដែលត្រូវមេត្តិយ និងភុម្មជកភិក្ខុគប្បីឲ្យលើសទោសព្រះទព្វមល្លបុត្ត ថាជាអ្នកសហាយនឹងភរិយារបស់ខ្លួនជាដំបូង ។

## សង្ឃដែលធ្វើកម្មនេះគប្បីតាំងក្នុងធម៌ ៣ យ៉ាងគឺ=

១–មត្តញ្ញុតា ជាអ្នកស្គាល់ប្រមាណ

២–កាលញ្ញុតា ជាអ្នកស្គាល់កាលវេលា

៣–បុគ្គលញ្ញុតា ជាអ្នកស្គាល់បុគ្គល ។

## កណ្ឌទី ៣២

## សង្ឃភេទនិងសាមគ្គី

## ហេតុដែលសង្ឃនឹងបែកគ្នាមាន ២ យ៉ាងគឺ=

១–មានសេចក្តីយល់ឃើញ ប្រាព្ធធម៌និងវិន័យផ្សេងគ្នាជាហេតុកើតវិវាទាធិករណ៍ ។

២–មានសេចក្តីបដិបត្តិមិនស្មើគ្នា គួរតែជាឯគ្នា កើតសេចក្តី

រវៀសគ្នាជាហេតុ ។

ក្នុងគម្ពីរបរិវារថាសង្ឃនឹងបែកគ្នាមាន ៥ យ៉ាងគឺ=

១– ដោយកម្មបានដល់សង្ឃកម្ម

២– ដោយឧទ្ទេសបានដល់សូត្របាតិមោក្ខ

៣– ដោយវោហាបានដល់ញត្តិ

៤– ដោយអនុសាវនា បានដល់ប្រកាសដោយកម្មវាចា

៥– ដោយឲ្យចាប់ស្លាក គឺបានដល់ឲ្យបោះឆ្នោតផ្តាច់ឈ្នះចាញ់ ។

## ទោសនៃសង្ឃភេទ

អ្នកណាបំលាយសង្ឃ ដែលព្រមព្រៀងគ្នា លោកថាអ្នកនោះត្រូវបានទទួលបាបធ្ងន់ថាន: អនន្តរិយកម្ម ធ្លាក់នរកអស់កល្ប ។

## សង្ឃភេទ

ភិក្ខុ ៤ ពួកសុទ្ធតែមានចំនួនគ្រប់សង្ឃទាំងអស់ គឺតាំងតែពី៤រូបឡើងទៅបំបែកគ្នាធ្វើឧបោសថ-បវារណា និងសង្ឃកម្មដទៃ ១ ហើយចាត់ជាសង្ឃភេទ

សង្ឃរាជី សេចក្តីប្រេះឆានៃសង្ឃមាន ៣ យ៉ាងគឺ=

១– ភិក្ខុ ២ ពួក ១ ពួកគ្រប់អង្គជាសង្ឃ ១ ពួកទៀតមិនគ្រប់អង្គជា

សង្ឃភិក្ខុញុះញង់ឲ្យបែកគ្នា ចាត់ជាសង្ឃរាជីគ្រាន់តែប្រេះឆា ។

២– ភិក្ខុ២ពួក សុទ្ធតែមានសង្ឃគ្រប់ចំនួន ភិក្ខុញុះញង់ឲ្យបែកអំពីគ្នា តែនៅមិនទាន់បែកគ្នា គឺនៅធ្វើសង្ឃកម្មនៅឡើយដូច្នេះនេះក៏ចាត់ជាសង្ឃរាជីដែរ ។

៣– ទ្រង់បញ្ញត្តិវត្តផ្សេងៗ ទុកដើម្បីភិក្ខុទាំងឡាយប្រព្រឹត្តជាមួយគ្នា តែភិក្ខុទាំងឡាយនោះមិនធ្វើមិនប្រព្រឹត្តចាត់ជាសង្ឃរាជី ។

## អ្នកដែលធ្វើសង្ឃភេទបាន

ចំពោះជាបកតត្តភិក្ខុមានសង្វាសស្មើគ្នា តាំងនៅក្នុងសីមាជាមួយគ្នា ហើយបែកជាពីរពួកយ៉ាងតិចក្នុង១ ពួកមានភិក្ខុ ៤ រូប មានអ្នកព្យាយាមបំបែក១ពួកទៀត ធ្វើសេចក្តីបំបែកបានតាមប្រាថ្នាហើយ រួមជា ៩ រូបដូច្នេះឈ្មោះថាសង្ឃភេទ ។

## អ្នកដែលធ្វើសង្ឃភេទមិនបាន

បានតែត្រឹមខ្វល់ខ្វាយនិងទំលាយគឺៈ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ។

## រឿងសង្ឃភេទបែកគ្នាដែលមានមកហើយនោះគឺ=

១– រឿងព្រះទេវទត្ត និងគណៈបានបែកចេញអំពីគណៈព្រះសាស្តា

២- សង្ឃវត្តឃោសិតារាម ក្រុងកោសម្ពីចែកគ្នាជា២ពួក

៣- សង្ឃវត្តអសោការាម ក្រុងបាដលីបុត្រ មិនព្រមព្រៀងគ្នា

៤- សង្ឃគណមហាវិហារ កើតរឿងសព្វកិច្ច អភយគិរីវិហារ ថាជាកុលទូសក ទីបំផុតក៏ចែកគ្នា លុះចែកគ្នាហើយ ក៏ញែកគ្នាធ្វើសង្ឃកម្ម ។

## នានាសង្វាសមាន ២ យ៉ាងគឺ=

១- ធ្វើខ្លួនឲ្យជានានាសង្វាសដោយខ្លួនឯង

២- សង្ឃព្រមព្រៀងគ្នាលើកចេញចាកសង្វាស ។

## សមានសំវាសមាន ២ យ៉ាងគឺ=

១- ធ្វើខ្លួនឲ្យជាសមានសំវាសដោយខ្លួនឯង

២- សង្ឃរម្ងាប់ឧក្ខេបនីយកម្មនោះចេញ ទទួលឲ្យចូលសំវាសតាមដើម ។

## សង្ឃសាមគ្គី

## សេចក្តីព្រមព្រៀងនៃសង្ឃមាន ២ យ៉ាងគឺ=

១- វិវាទាធិករណ៍ រម្ងាប់ដោយការផ្សះផ្សាគ្នាឯង ឬព្រមទទួលបេ-

សសង្ឃ២ពួកទៀត ។

២– អាបត្តាធិករណ៍ រម្ងាប់ដោយតិណវត្ថារកវិន័យ គឺដោយផ្សះផ្សាគ្នា មិនបាច់ការរកហេតុនៃសេចក្តីខុសរបស់គ្នានឹងគ្នា ។

## ពាក្យសរសើរអ្នកធ្វើសង្ឃសាមគ្គីថាៈ

អ្នកធ្វើសង្ឃដែលបែកបាក់គ្នាហើយ ឲ្យព្រមព្រៀងគ្នាឡើងវិញ រមែងបានព្រហ្មបុណ្យ គឺបុណ្យយ៉ាងខ្ពស់ទឹង បានរីករាយក្នុងស្ថានសួគ៌ រហូតកប្ប ។

## សាមគ្គីឧបោសថ

ភិក្ខុគប្បីប្រជុំគ្នាទាំងអស់ ភិក្ខុ១រូបប្រកាសសេចក្តីសាមគ្គី ដោយញត្តិទុតិយកម្មតាមរបៀបហើយ គប្បីសូត្របាតិមោក្ខឡើង ។

## កណ្ឌទី ៣៣

## បកិណ្ណកៈ

### ១– ការលាសិក្ខាបទ

ភិក្ខុកាលដែលនឿយណាយ ចំពោះការប្រព្រឹត្តិព្រហ្មចរិយធម៌ហើយ ប្រាថ្នានឹងត្រឡប់ទៅជាគ្រហស្ថវិញ រមែងធ្វើបានដោយការលាសិក្ខាបទ គឺថ្លែងខ្លួនចំពោះមុខភិក្ខុដូចគ្នា ឬចំពោះមុខគ្រហស្ថ រូបហើយ

លះហេតុនោះចេញកាន់យកហេតុដែលខ្លួនប្ដេជ្ញា ។

## ខេត្តដែលគួរអាងដល់នោះគឺ—

១– លាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សិក្ខា វិន័យ បាតិមោក្ខ ឧទ្ទេស ឧបជ្ឈាយ៍ អាចារ្យ សទ្ធិវិហារិក អន្តេវាសិក សមានុបជ្ឈាយក សមានាចារិក សហព្រហ្មចារី ។

២–ប្ដេជ្ញាជាគ្រហស្ថ ជាឧបាសក ជាអារាមិក ជាសាមណេរ ជាតិរ្ថិយ៍ ជាសាវកតិរ្ថិយ៍ ។

៣– បដិសេធសេចក្ដីជាសមណៈ សេចក្ដីជាសក្យបុត្តិយចេញ

៤– សំដែងសេចក្ដីមិនជាប់ជំពាក់ដោយវត្ថុជាខេត្តលាណាមួយក៏បាន ។

## ការលាសិក្ខាត្រូវធ្វើជាកិច្ចលក្ខណដូច្នេះគឺ—

១– ត្រូវតាំងចិត្តដើម្បីលាសិក្ខាពិត ។

២–ប្ដេជ្ញាដោយពាក្យជាចំនាត

៣– បញ្ចេញវាចាប្ដេជ្ញាដោយខ្លួនឯង

៤– អ្នកប្ដេជ្ញា ជាមនុស្សធម្មតាមិនមែនឆ្កួត

៥– អ្នកទទួលពាក្យប្ដេជ្ញា ចូលចិត្តក្នុងពាក្យនោះពេញទី ជាភាសា

ស្តាប់គ្នាបាន ។

ការទន្ទេញពាក្យលាសិក្ខា ដោយមិនបានតាំងចិត្តនឹងលាសិក្ខាមិនរាប់ថាលាសិក្ខា ពោលពាក្យរំពឹង ពាក្យបរិកប្ប ពាក្យដែលអាងថាធ្លាប់ធ្វើមកហើយ ឬនឹងធ្វើទៅខាងមុខ ដូច្នោះក៏មិនរាប់ថាលាសិក្ខាដែរ ។

ត្រូវប្រើពាក្យ ដាច់ខាត ជាបច្ចុប្បន្នកាលថា សិក្ខំ បច្ចក្ខាមិ ប្រែថា ខ្ញុំម្ចាស់លាសិក្ខា ឬនឹងថា គិហីតិ មំ ធារេថ ប្រែថា លោកម្ចាស់ទាំងឡាយ ចូរចាំខ្ញុំម្ចាស់នេះជាគ្រហស្ថ ឥឡូវនឹងរួមគ្នាថា
សិក្ខំ បច្ចក្ខាមិ គិហីតិ មំ ធារេថ ប្រែថា ខ្ញុំម្ចាស់លាសិក្ខា សូមលោកម្ចាស់ទាំងឡាយ ចូរចាំខ្ញុំម្ចាស់នេះថាជាគ្រហស្ថ; ពោលដូច្នេះនេះឈ្មោះថាលាសិក្ខាពេញលក្ខណៈ ។ លុះកាន់ភេទជាគ្រហស្ថហើយ ត្រូវសំដែងខ្លួនជាឧបាសកម្តងទៀត គឺត្រូវទទួលនិច្ចសីល ដើម្បីជាចំណងចិត្ត មិនឲ្យឃ្លាតចាកសីលឆ្ងាយពេក ។ ចំពោះសាមណេរមិនមានពាក្យលា កាលបើត្រូវលះភេទជាសាមណេរចេញ គ្រាន់តែផ្លាស់សំពត់កាសាយហើយកាន់យកភេទជាគ្រហស្ថ តែត្រូវធ្វើកិច្ចជាលក្ខណ ក៏ឈ្មោះថាសឹក ឬនឹងពោលពាក្យថា សិក្ខំ បច្ចក្ខាមិ ក៏បាន តែត្រង់ពាក្យ គិហិនោះមិនចាំបាច់ថាព្រោះនៅក្មេង នឹងហៅថាគ្រហស្ថ

មិនទាន់បាន ព្រោះពាក្យថាគ្រហស្ថនេះ បានដល់អ្នកនៅគ្រប់គ្រងផ្ទះ.

ហដ្ឋាន ។

## ២– នាសនៈ

ស័ព្ទនេះ ប្រែថា ឱ្យសឹកឬឱ្យវិនាស

មនុស្សដែលទ្រង់អនុញ្ញាតឱ្យនាសនៈមាន ៣ យ៉ាងគឺ=

១– ភិក្ខុត្រូវអន្តិមវត្ថុហើយ នៅប្តេជ្ញាខ្លួនជាភិក្ខុ

២– បុគ្គលអ្នកឧបសម្បទមិនឡើង បានទទួលឧបសម្បទពីសង្ឃ

៣– សាមណេរប្រព្រឹត្តហាយនៈ ដែលប្រកបដោយអង្គ ១០ ។

ឱ្យនាសនៈសាមណេរ ដែលប្រកបដោយអង្គ ១០គឺៈ

១– ជាអ្នកបំផ្លាញជីវិតសត្វ ដោយប្រក្រតី

២– ជាអ្នកលួច

៣– ជាអ្នកសេពមេថុន

៤– ជាអ្នកកុហក

៥– ជាអ្នកផឹកសុរា

៦– ជាអ្នកតិះដៀលព្រះពុទ្ធ

៧– ជាអ្នកតិះដៀលព្រះធម៌

៨– ជាអ្នកតិះដៀលព្រះសង្ឃ

៩– ជាអ្នកមិច្ឆាទិដ្ឋិ

១០– ជាអ្នកប្រទុស្តភិក្ខុនី ។

## អាការនាសនៈមាន ៣ យ៉ាងគឺ=

១– លិង្គនាសនា ឲ្យវិនាសចាកភេទ

២– សម្ភោគនាសនា ឲ្យវិនាសចាកការរួមបរិភោគ

៣– សំវាសនាសនា ឲ្យវិនាសចាកសង្វាស ។

## ៣– ទណ្ឌកម្ម

សាមណេរធ្វើខុសមានទោសមិនដល់នាសនៈ ឲ្យដាក់ទណ្ឌកម្មសាមណេរ

ដែលប្រកបដោយអង្គ ៥ យ៉ាងគឺ:

១– ខ្វល់ខ្វាយដើម្បីមិនមែនលាភនៃភិក្ខុទាំងឡាយ

២– ខ្វល់ខ្វាយដើម្បីមិនជាប្រយោជន៍នៃភិក្ខុទាំងឡាយ

៣– ខ្វល់ខ្វាយដើម្បីនៅមិនបាននៃភិក្ខុទាំងឡាយ

៤– ជេរបញ្ឆិតបញ្ឆៀននៃភិក្ខុទាំងឡាយ

៥– ញុះញង់ភិក្ខុទាំងឡាយឲ្យបែកគ្នា ។

កាលបើសាមណេររូបណាមួយប្រព្រឹត្តខុសយ៉ាងនេះសង្ឃគួរធ្វើទណ្ឌកម្មៗ

## ម៉្យាងទៀតគឺ =

១– ជាអ្នកប្រព្រឹត្តកន្លងសិក្ខាបទ៥ខាងចុងមានវិកាលភោជនជាដើម

២– ជាអ្នកប្រព្រឹត្តមិនអើពើក្នុងកិច្ចវត្ត ដែលគប្បីសិក្សា ។

បើធ្វើខុសយ៉ាងនេះអ្នកគ្រប់គ្រងត្រូវធ្វើទណ្ឌកម្មដល់សាមណេរនោះៗ ។

## ការធ្វើទណ្ឌកម្មហាមមិនឱយធ្វើធ្ងន់ពេកដូចជា:

២ ហាមមិនឲ្យឆាន់អាហារ

២– ឲ្យដេកលើផែនដីដ៏ក្តៅ

៣– ឲ្យទូលរបស់ធ្ងន់ដូចជាថ្មឥដ្ឋលើក្បាល

៤– ឲ្យចុះត្រាំទឹក ។

## ឱយធ្វើតែល្មមគួរសមដូចជាៈ

១– កំណត់ឲ្យនៅក្នុងខេត្រដែលកំណត់

២– ឲ្យដងទឹក

៣– ឲ្យជញ្ជូនឧស

៤– ឲ្យជញ្ជូនខ្សាច់ឬលាងសំអាតអាសនឬសេនាសនក្នុងទីវត្តជាដើម

## ៤– ប្រណាម

ការកាត់បង់អ្នកប្រព្រឹត្តមិនប្រពៃ មិនសេពគប់ផងហៅថា ប្រណាម ប្រែថា ច្រានចេញ, ឲ្យធ្វើដល់សហធម្មិកក៏មាន ដល់គ្រហស្ថក៏មាន ។

## ប្រណាមមាន ២ យ៉ាងគឺ=

១– ប្រណាមជាការសង្ឃ

២– ប្រណាមជាការបុគ្គល ៕

## ប្រណាមជាការសង្ឃមាន ៤ យ៉ាងគឺ=

១– ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដូចបានពោលមកហើយខាងលើ

២– ផ្កាប់បាត្រដល់ឧបាសក ដែលប្រកបដោយទោស៨យ៉ាង

៣– ដាក់ព្រហ្មទណ្ឌ ដូចសង្ឃធ្វើដល់ព្រះឆន្ន

៤– បណ្ដេញសាមណេរចេញចាកគណៈពាំងគេ ៕

## ប្រណាមជាការបុគ្គលគឺ=

ព្រះឧបជ្ឈាយ៍និងអាចារ្យ ប្រណាមសទ្ធិវិហារិកនិងអន្តេវាសិកដែលប្រព្រឹត្តមិនសមរម្យ ៕

# ភាគកម្មវាចាសីមា

## ពាក្យសូធ្យដកតិចីវរាវិប្បវាស

សុណាតុ មេ ភន្តេ សង្ឃោ យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនតិ យស្សាយស្មតោ ខមតិ ឯតស្ស តិចីវរេន អវិប្បវាសស្ស សមុគ្ឃាតោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សមូហតោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ , បើសេចក្តីព្រម-ព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីដកដែនមិននៅប្រាសចាកត្រៃចីវរ ដែលសង្ឃបានសន្មតទុកហើយ នេះជាញត្តិ ។ (គឺវាចាប្រកាសឲ្យដឹងសេក្តី)

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ , ដែលសង្ឃដកៈនៈ

គឺដែនមិននៅប្រាសចាកត្រៃចីវរ ដែលសង្ឃសន្មតទុកហើយ ការដកដែនមិននៅប្រាសចាកត្រៃចីវរនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះ គប្បីនៅស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះ គប្បីនិយាយឡើង ដែនមិននៅប្រាសចាកត្រៃចីវរនោះ ដែលសង្ឃដកហើយ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបស្ងៀមនៅ ខ្ញុំម្ចាស់ចាំទុកនូវសេចក្តីស្ងៀមនេះដោយប្រការដូច្នេះ ។

## សូធ្យដកសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ សមូហនេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា សង្ឃោ តំ សីមំ សមូហនតិ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ សមានសំវាសាយ ឯកុបោសថាយ សមុគ្ឃាតោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សមូហតា សា សីមា សង្ឃេន សមានសំវាសា ឯកុបោសថា ខមតិ សង្ឃស្ស

តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីដកសីមា ដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នាទុកហើយនេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន ដែលសង្ឃដកនេះ គឺសីមាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នាទុកហើយ ការដកសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីជាអ្នកស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីនិយាយឡើង សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ ដែលសង្ឃដកហើយ គាប់ចិត្តដល់សង្ឃ ហេតុនេះទើបស្ងៀម ខ្ញុំចាំទុកសេចក្តីនេះទុកដោយប្រការយ៉ាងនេះ ៗ

## ពាក្យសូធ្យសួរនិមិត្ត

១– ទិសឯកើតជា បុរត្ថិមាយ ទិសាយ កឹ និមិត្តំ? ទិសឯកើតមានអ្វីជានិមិត្ត ?

២– ទិសអគ្នេយ៍ថា បុរត្ថិមាយ អនុទិសាយ គឺ និមិត្តំ? ទិសអគ្នេយ៍ មានអ្វីជានិមិត្ត ?

៣– ទិសឯត្បូងថា ទក្ខិណាយ ទិសាយ គឺ និមិត្តំ? ទិសឯត្បូង មានអ្វីជានិមិត្ត ?

៤– ទិសនិរតីថា ទក្ខិណាយ អនុទិសាយ គឺ និមិត្តំ? ទិសនិរតីមានអ្វី ជានិមិត្ត ?

៥– ទិសឯលិចថា មច្ឆិមាយ ទិសាយ គឺ និមិត្តំ ? ទិសឯលិចមានអ្វី ជានិមិត្ត ?

៦– ទិសពាយ័ព្យថា មច្ឆិមាយ អនុទិសាយ គឺ និមិត្តំ ? ទិសពាយ័ព្យ មានអ្វីជានិមិត្ត?

៧– ទិសឧត្តរថា ឧត្តរាយ ទិសាយ គឺ និមិត្តំ ? ទិសឧត្តរមានអ្វីជា និមិត្ត ?

៨– ទិសឦសានថា ឧត្តរាយ អនុទិសាយ គឺ និមិត្តំ? ទិសឦសាន មានអ្វីជានិមិត្ត ?

៩– ទិសឯកើតម្តងទៀតថា បុរត្ថិមាយ ទិសាយ គឺ និមិត្តំ? ទិស ឯកើតមានអ្វីជានិមិត្ត ?

# ពាក្យឆ្លើយសិលានិមិត្ត

១—បាសាណោ កន្តេ ថ្មលោកម្ចាស់

២—បព្វតោ កន្តេ ភ្នំលោកម្ចាស់

៣—វនំ កន្តេ ព្រៃលោកម្ចាស់

៤ រុក្ខោ កន្តេ ដើមឈើលោកម្ចាស់

៥—មគ្គោ កន្តេ ផ្លូវលោកម្ចាស់

៦—វម្មិកោ កន្តេ តម្បូកលោកម្ចាស់

៧—នទី កន្តេ ស្ទឹងលោកម្ចាស់

៨—ឧទកំ កន្តេ ទឹកលោកម្ចាស់

## សម្តែងសរឈ្មោះសិលានិមិត្តជាតួយ៉ាងថាដូច្នេះ

១— ឯសោ បាសាណោ និមិត្តំ សិលានោះជានិមិត្ត

២— ឯសោ បព្វតោ និមិត្តំ ភ្នំនោះជានិមិត្ត

៣— ឯតំ វនំ និមិត្តំ ព្រៃនោះជានិមិត្ត

៤— ឯសោ រុក្ខោ និមិត្តំ ដើមឈើនោះជានិមិត្ត

៥— ឯសោ មគ្គោ និមិត្តំ ផ្លូវនោះជានិមិត្ត

៦— ឯសោ វម្មិកោ និមិត្តំ តម្បូកនោះជានិមិត្ត

៧–ឯសោ នទី និមិត្តំ　　ស្ទឹងនោះជានិមិត្ត

៨–ឯតំ ឧទកំ និមិត្តំ　　ទឹកនោះជានិមិត្ត ។

## ពាក្យសន្មតសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា និមិត្តា កិត្តិតា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នេយ្យ សមានសំវាសំ ឯកុបោសថំ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា និមិត្តា កិត្តិតា សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នតិ សមានសំវាសំ ឯកុបោសថំ យស្សាយស្មតោ ខមតិ ឯតេហិ និមិត្តេហិ សីមាយ សម្មុតិ សមានសំវាសាយ ឯកុបោសថាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតា សីមា សង្ឃេន ឯតេហិ និមិត្តេហិ សមានសំវាសា ឯកុបោសថា ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន　សូមសង្ឃចូរស្ដាប់ខ្ញុំ និមិត្តសឈ្មោះទុកដោយជុំវិញហើយត្រឹមណា　បើសេចក្ដីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីសន្មតសីមា　ឲ្យមានសំវាសស្មើគ្នា មានឧបោសថជា

មួយគ្នា ដោយនិមិត្តតាំងនោះ នេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃចូរស្ដាប់ខ្ញុំ និមិត្តសឈ្មោះទុក ហើយដោយជុំវិញត្រឹមណា សង្ឃសន្មតឥឡូវនេះ នូវសីមាឲ្យមានសំ-វាសស្មើគ្នាមានឧបោសថជាមួយគ្នា ដោយនិមិត្តតាំងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីជាអ្នកស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីនិយាយឡើង សីមាដែលសង្ឃសន្មត ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ហើយដោយនិមិត្តតាំងនោះ រមែងគាប់ចិត្តដល់សង្ឃ ហេតុនោះទើបនៅស្ងៀម ខ្ញុំម្ចាស់ចាំនូវសេចក្ដីនេះដោយប្រការដូច្នេះ ។

## សូធ្យសន្មតតិចីវរាវិប្បវាស

សុណាតុ មេ ភន្តេ សង្ឃោ **យា** សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នេយ្យ ឋបេត្វា គាមញ្ច គាមូបចារញ្ច ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា សង្ឃោ តំ សីមំ តិចីវរេន

អវិប្បវាសំ សម្មន្នតិ ឋបេត្វា គាមញ្ច គាមុបចារញ្ច យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ តិចីវរេន អវិប្បវាសស្ស សម្មតិ ឋបេត្វា គាមញ្ច គាមុបចារញ្ច សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតា សា សីមា សង្ឃេន តិចីវរេន អវិប្បវាសោ ឋបេត្វា គាមញ្ច គាមុបចារញ្ច ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ៗ

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃចូរស្តាប់ខ្ញុំ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីសន្មតសីមាដែលសង្ឃអនុមតិឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នាទុកហើយ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរចាកភូមិនិងឧបចារនៃភូមិទុក នេះជាញត្តិ ៗ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវនេះនូវសីមា ដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នាទុកហើយ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរភូមិនិងឧបចារនៃភូមិទុក ការសន្មតិសីមានេះ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរចាកភូមិ និងឧបចារនៃភូមិទុក គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីនៅស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា

លោកម្ចាស់អង្គនោះគប្បីនិយាយឡើង សីមានោះ សង្ឃសន្មតឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរហើយ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបនៅស្ងៀម ខ្ញុំម្ចាស់ចាំទូវសេចក្តីនេះទុក ដោយប្រការយ៉ាងនេះ ។

## សូធ្យសម្មតិភ្នាក់ងារធ្វើការសង្ឃ

១ - ក្នុងអធិការនៃចីវរ សម្តែងពាក្យសម្មតិចីវរភាជកទុកជាតួយ៉ាង៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរភាជកំ សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរភាជកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ចីវរភាជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ចីវរភាជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃចូរស្តាប់ខ្ញុំ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សូមសង្ឃចូរសន្មតភិក្ខុ «ឈ្មោះនេះ»

---

(១) សំរាប់បញ្ចូលនាមប្បញ្ញត្តិភិក្ខុ

ទុកជាអ្នកចែកចីវរនេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុ «មានឈ្មោះយ៉ាងនេះ» ជាអ្នកចែកចីវរ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីនិយាយឡើង «ភិក្ខុមានឈ្មោះយ៉ាងនេះ» សង្ឃសន្មតិទុកជាអ្នកចែកចីវរហើយ ការសន្មតិគាប់ចិត្តដល់សង្ឃ ហេតុនេះទើបស្ងៀម ខ្ញុំចាំនូវសេចក្តីនោះទុក ដោយប្រការយ៉ាងនេះ ។

២– ពាក្យសូត្រសម្មតិទៅអធិការនៃអាហាររួមផុរៈផង, ចូលក្នុងកម្មវាចា ជាមួយគ្នាដូច្នេះ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភត្តុទ្ទេសកញ្ច យាគភាជកញ្ច ផលភាជកញ្ច ខជ្ជភាជកញ្ច សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភត្តុទ្ទេសកញ្ច យាគុភាជកញ្ច ផលភាជកញ្ច ខជ្ជភាជកញ្ច សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភត្តុទ្ទេសកស្ស ច យាគុភាជកស្ស ច ផលភាជកស្ស ច ខជ្ជភាជកស្ស ច សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ភត្តុទ្ទេសកោ

ច យាគុភាជកោ ច ផលភាជកោ ច ខជ្ជភាជកោ ច ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

៣ ទៅអធិការនៃសេនាសនៈ ពាក្យសន្មតិសេនាសនគាហាបកជា ដូច្នេះ ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ- (ឥត្ថន្នាមំ) ភិក្ខុំ សេនាសនគាហាបកំ សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សេនាសនគាហាបកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុ- នោ សេនាសនគាហាបកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខម- តិ សោ ភាសេយ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ សេនា សនគាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

៤–ពាក្យសូធ្យសម្មតិទៅអធិការនៃអារាមជាដូច្នេះ ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អារាមិកបេសកំ សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អារាមិកបេ សកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អា

រាមិកបេសកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេ-យ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ អារាមិកបេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

៥– ពាក្យសូធ្យសម្មតិទៅអធិការនៃឃ្លាំង, សម្មតិភណ្ឌាគារិក ជាដូច្នេះ ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិកំ សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិ-កំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភណ្ឌាគារិកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ភណ្ឌាគារិកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

៦– ពាក្យសម្មតិ អប្បមត្តកវិសជ្ជក គប្បីដឹងដោយធៀបគ្នាពាក្យសូធ្យជាដូច្នេះ ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិកញ្ច អប្បមត្តកញ្ច សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិកញ្ច អប្បមត្តកញ្ច សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភណ្ឌាគារិកស្ស ច អប្បមត្តកស្ស ច សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ភណ្ឌាគារិកោ ច អប្បមត្តកោ ច ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## បែបកម្មវាចាសូធ្យឱយសំពត់កឋិន

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស (ឥត្ថន្នាមស្ស) ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ កឋិនំ អត្ថរិតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

# ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃចូរស្តាប់ខ្ញុំ សម្ពត់កឋិននេះកើតឡើងហើយដល់សង្ឃ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីឲ្យសំពត់កឋិននេះដល់ភិក្ខុមានឈ្មោះ ( ... ) នេះដើម្បីក្រាលកឋិននេះជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃចូរស្តាប់ខ្ញុំ សំពត់កឋិននេះកើតឡើងហើយដល់សង្ឃ សង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុមានឈ្មោះ(..) នេះដើម្បីក្រាលកឋិន ការឲ្យសំពត់កឋិននេះដល់ភិក្ខុមានឈ្មោះ(..)នេះ ដើម្បីក្រាលកឋិន រមែងគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីជាអ្នកនៅស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីនិយាយឡើង សំពត់កឋិននេះ សង្ឃឲ្យហើយដល់ភិក្ខុមានឈ្មោះ(..)នេះដើម្បីក្រាលកឋិនរមែងគាប់ចិត្តដល់សង្ឃ ហេតុនេះទើបនៅស្ងៀម ខ្ញុំម្ចាស់ចាំនូវសេចក្តីនេះទុក ដោយប្រការយ៉ាងនេះ ។

## វុដ្ឋានវិធីនៃសញ្ចេតនិកាបត្តិសំរាប់អបដិច្ឆន្នាបត្តិតែមួយ

## ពាក្យសុំមានត្ត

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ

សោហំ ភន្តេ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមិ ។

អហំ ភន្តេ ឯកំ អាបត្តឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ ទុតិយម្បិ ភន្តេ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមិ ។

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ តតិយម្បិ ភន្តេ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចាមិ ។

## ពាក្យប្រែ

បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់បានត្រូវអាបត្តិមួយឈ្មោះ សញ្ចេតនិកា សុក្កវិសដ្ឋិ មិនបានបិទបាំងទុក លោកម្ចាស់ ខ្ញុំម្ចាស់សូមមានត្ត៦រាត្រីដើម្បី អាបត្តិមួយ១ឈ្មោះសញ្ចេតនិកា សុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកចំពោះសង្ឃ ។ល។ ខ្ញុំម្ចាស់សូមជាគំរប់ ២ ដង ។ល។ ខ្ញុំម្ចាស់សូមជាគំរប់ ៣ ដង ។

## កម្មវាចាឱយមានត្ត

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ

អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ទទេយ្យ ឯសា ញត្តិ ៗ

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ទុតិយម្បិ ឯតមត្ថំ វទាមិ ៗ

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចតិ

សង្ឃោ(ឥត្ថន្នាមស្ស) ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តស្ស ទាន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ តតិយម្បិ ឯតមត្ថំ វទាមិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ(ឥត្ថន្នាមោ)ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អប្បដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស)ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស)ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ទិន្នំ សង្ឃេន(ឥត្ថន្នាមស្ស)ភិក្ខុនោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប្បដិច្ឆន្នាយ ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះ រូបនេះបានត្រូវអាបត្តិមួយឈ្មោះ សញ្ចេតនិកា សុក្កវិសដ្ឋិ មិនបានបិទបាំងទុក ភិក្ខុនេះសូមមានត្ត ៦ រាត្រី ដើម្បីអាបត្តិមួយ ឈ្មោះសញ្ចេតនិកា សុក្កវិសដ្ឋិដែលមិនបានបិទបាំងទុកចំពោះសង្ឃ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីឲ្យមានត្ត ៦ រាត្រី ដើម្បីអាបត្តិមួយ១ ឈ្មោះសញ្ចេតនិកា សុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកដល់ភិក្ខុឈ្មោះនេះ (នេះជាញត្តិប្រកាសឲ្យដឹង) ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះ រូបនេះ បានត្រូវអាបត្តិមួយឈ្មោះ សញ្ចេតនិកា សុក្កវិសដ្ឋិ មិនបានបិទបាំងទុក លោកនេះសុំមានត្ត ៦ រាត្រី ដើម្បីអាបត្តិមួយ១ឈ្មោះសញ្ចេតនិកា សុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកចំពោះសង្ឃ សង្ឃឲ្យមានត្ត ៦រាត្រី ដល់ភិក្ខុឈ្មោះនេះការឲ្យមានត្ត ៦ រាត្រី ដល់ភិក្ខុឈ្មោះ នះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីជាអ្នកស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីនិយាយឡើង ខ្ញុំម្ចាស់ពោលសេចក្តីនេះជាគំរប់ ២ ដង ។ល។ ជាគំរប់ ៣ ដង ។ល។ មានត្ត ៦ រាត្រី ដើម្បីអាបត្តិមួយ១ឈ្មោះ សញ្ចេតនិកា សុក្កវិសដ្ឋិ ដែល

មិនបានបិទបាំងទុក សង្ឃឲ្យហើយដល់ភិក្ខុឈ្មោះនេះ ត្រូវដល់សង្ឃ ហេតុនេះទើបនៅស្ងៀម ខ្ញុំម្ចាស់ចាំនូវសេចក្ដីនេះទុក ដោយប្រការយ៉ាងនេះ ។

## ពាក្យសមាទានមានត្តថា ៖

មានត្តំ សមាទិយាមិ វត្តំ សមាទិយាមិ(១)

ខ្ញុំម្ចាស់សមាទានមានត្ត ខ្ញុំម្ចាស់លើកវត្ត ។

## ពាក្យប្រាប់មានត្តថា ៖

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អប-ដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ អាបត្តិយា សញ្ចេ-តនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ មានត្តំ ចរាមិ វេទយា អហំ ភន្តេ វេទយតីតិ មំ សង្ឃោ ធារេតុ ។

## ពាក្យប្រែ

បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់បានត្រូវអាបត្តិមួយឈ្មោះសញ្ចេតនិក-សុក្កវិសដ្ឋិ មិនបានបិទបាំងទុក ខ្ញុំម្ចាស់បានសូមមានត្ត ៦ រាត្រី ដើម្បីអាបត្តិមួយខឈ្មោះ ( . . . ) ដែលមិនបានបិទបាំងទុកចំពោះសង្ឃ សង្ឃ

(១) ទុតិយម្បិ ..., តតិយម្បិ ... ។

បានឲ្យមានត្ត ៦ រាត្រី ដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់កំពុងប្រព្រឹត្តមានត្តនៅ

បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ប្រាប់ឲ្យជ្រាប សូមសង្ឃចូរចាំខ្ញុំម្ចាស់ ទុកជាប្រាប់ឲ្យជ្រាបហើយ ។

បើប្រាប់ដល់ភិក្ខុ ៣ រូបថា អាយស្មន្តា ធារេន្តុ បើភិក្ខុ ២ រូប ថា អាយស្មន្តា ធារេន្តុ បើភិក្ខុ ១ រូបថា អាយស្មា ធារេតុ ជំនួសពាក្យថា សង្ឃោ ធារេតុ ។

## ពាក្យដាក់មានត្តថា ៖

វត្តំ និក្ខិបាមិ មានត្ត និក្ខិបាមិ(១)

ខ្ញុំម្ចាស់ដាក់វត្ត ខ្ញុំម្ចាស់ដាក់មានត្ត ។

## ពាក្យសុំអព្ភាន

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចាមិ ។

(១) ទុតិយម្បិ..., តតិយម្បិ... ។

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ ចិណ្ណមានត្តោ ទុតិយម្បិ ភន្តេ សង្ឃំ អព្ភានំ យាចាមិ ។

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោហំ ចិណ្ណមានត្តោ តតិយម្បិ ភន្តេ សង្ឃំ អព្ភានំ យាចាមិ ។

## ពាក្យប្រែ

បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់បានត្រូវអាបត្តិមួយឈ្មោះសញ្ចេតនិកា សុក្កសវិសដ្ឋិ មិនបានបិទបាំងទុក ខ្ញុំបានសុំមានត្ត ៦ រាត្រី ចំពោះសង្ឃ សង្ឃបានឲ្យមានត្ត៦រាត្រី (...) ដល់ខ្ញុំម្ចាស់ បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ប្រព្រឹត្តមានត្តហើយសូមអព្ភានចំពោះសង្ឃ ។ល។ ខ្ញុំម្ចាស់សុំជាគំរប់ ២ ដងផង ។ល។ ខ្ញុំម្ចាស់សុំជាគំរប់៣ដង ។

# កម្មវាចាឱយអព្ភាន

សុណាតុ មេ ភន្តេ សង្ឃោ អយំ ( ឥត្ថន្នាមោ ) ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ តស្ស សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ តស្ស សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ទុតិយម្បិ ឯតមត្ថំ វទាមិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋិំ អបដិច្ឆន្នំ សោ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ តស្ស សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ តតិយម្បិ ឯតមត្ថំ វទាមិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ ឯកំ អាបត្តឹ អាបជ្ជិ សញ្ចេតនិកំ សុក្កវិសដ្ឋិំ អបដិច្ឆន្នំ សោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ យាចិ តស្ស សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិសដ្ឋិយា អបដិច្ឆន្នាយ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស តស្មា

តុណ្ហី ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះ រូបនេះបានត្រូវអាបត្តិមួយ១ឈ្មោះសញ្ចេតនិកាសុក្កវិសដ្ឋិ មិនបានបិទបាំងទុកលោកបានសុំមានត្ត៦រាត្រី(· ·)ចំពោះសង្ឃ សង្ឃបានឲ្យមានត្ត៦រាត្រីដល់លោក លោកប្រព្រឹត្តមានត្តហើយ សូមអព្ភានចំពោះសង្ឃ បើសេចក្តីព្រមព្រៀងរបស់សង្ឃដល់ទីហើយ សង្ឃគប្បីអព្ភានភិក្ខុឈ្មោះនេះ នេះជាវាចាប្រកាសឲ្យជ្រាប ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះ រូបនេះ បានត្រូវអាបត្តិមួយឈ្មោះ( . . . . )មិនបានបិទបាំងទុក លោកបានសុំមានត្ត៦រាត្រី ( . . . ) ចំពោះសង្ឃ សង្ឃបានឲ្យមានត្ត៦រាត្រី ( . . . . ) ដល់លោក លោកប្រព្រឹត្តហើយ សុំអព្ភានចំពោះសង្ឃ សង្ឃអព្ភានលោក ការអព្ភានលោកនេះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីជាអ្នកស្ងៀម បើមិនគួរដល់លោកអម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីនិយាយឡើង ខ្ញុំម្ចាស់ពោលសេចក្តីនេះជាគំរប់ ២ដង ។ល ។ ជាគំរប់៣ដង ។ល ។ ភិក្ខុឈ្មោះនេះដែលសង្ឃអព្ភានហើយ

គួរដល់សង្ឃ ហេតុនេះទើបស្មៀននៅ ខ្ញុំម្ចាស់ចាំនូវសេចក្ដីនេះទុក ដោយប្រការយ៉ាងនេះ ។

## បែបកម្មវាចាឱ្យឧបសម្បទ

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ នាគំ ឧបសម្បាទេយ្យ អាយស្មតា តិស្សេន ឧបជ្ឈាយេន ឯសា ញត្តិ ។

## ប្រែថា

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ផ្ទៀតសាមណេរឈ្មោះនាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សដ៏មានអាយុជាអ្នកសំឡឹងយកនូវឧបសម្បទា បរិសុទ្ធផុតចាកអន្តរាយិកធម៌ទាំងឡាយហើយ បាត្រនិងចីវររបស់ (សាមណេរឈ្មោះនាគ) មានគ្រប់គ្រាន់ហើយ សាមណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សដ៏មានយុ ជាព្រះឧបជ្ឈាយ៍ មកសូមឧបសម្បទានឹងព្រះសង្ឃបើ (ឧបសម្បទាកម្មនេះ) ជាបត្តកល្ល គឺមានកាលដ៏សមគួរដល់ព្រះសងហើយ ព្រះសង្ឃគប្បីញុំាងសាមណេរ

ឈ្មោះនាគមានព្រះថេរៈឈ្មោះតិស្សដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ ឲ្យបាន
នូវឧបសម្បទា ពាក្យនេះជាពាក្យសំរាប់ញុំាងសង្ឃឲ្យដឹង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស
ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស
បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧប
ជ្ឈាយេន សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈា
យេន យស្សាយស្មតោ ខមតិ នាគស្ស ឧបសម្បទា អាយស្មតា
តិស្សេន ឧបជ្ឈាយេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេ-
យ្យ ទុតិយម្បិ ឯតមត្ថំ វទាមិ ។

## ប្រែថា

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ផ្សិកសាមណេរឈ្មោះ
នាគនេះ (ជាសទ្ធិវិហារិក) នៃព្រះថេរៈឈ្មោះតិស្សដ៏មានអាយុជាអ្នក
សំឡឹងយកនូវឧបសម្បទា បរិសុទ្ធផុតចាកអន្តរាយិកធម៌ទាំងឡាយហើយ
បាត្រនិងចីវររបស់ (សាមណេរឈ្មោះនាគនេះ) មានគ្រប់គ្រាន់ហើយ
សាមណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សដ៏មានអាយុ ជាព្រះឧប-
ជ្ឈាយ៍ មកសូមឧបសម្បទា និងព្រះសង្ឃ ព្រះសង្ឃក៏បានញុំាងសាម-

ណេរឈ្មោះនាគ មានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ ឲ្យបាននូវឧបសម្បទា កាលដែលឲ្យនូវឧបសម្បទា ដល់សាមណេរឈ្មោះនាគមានព្រះថេរៈឈ្មោះតិស្សៈដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ (នេះ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម បើមិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ខ្ញុំព្រះករុណាពោលនូវសេចក្តីនេះ ជាគំរប់ ២ ដងផង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈា-យេន យស្សាយស្មតោ ខមតិ នាគស្ស ឧបសម្បទា អាយស្មតា តិស្សេន ឧបជ្ឈាយេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ តតិយម្បិ ឯតមត្ថំ វទាមិ ។

## ប្រែថា

បពិត្រព្រះសង្ឃដ៏ចំរើន ។ល។ ខ្ញុំព្រះករុណា ពោលនូវសេចក្តីនេះ ជាគំរប់ ៣ ដងផង ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន យស្សាយស្មតោ ខមតិ នាគស្ស ឧបសម្បទា អាយស្មតា តិស្សេន ឧបជ្ឈាយេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ

ប្រែថា

បពិត្រព្រះសង្ឃដ៏ចំរើន ។ល។ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ឧបសម្បន្នោ សង្ឃេន នាគោ អាយស្មតា តិស្សេន ឧបជ្ឈាយេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

ប្រែថា

សាមណេរឈ្មោះនាគ (នេះ) មានព្រះថេរៈឈ្មោះតិស្សដ៏មានអាយុ ជាព្រះឧបជ្ឈាយ៍ គឺការកសង្ឃឲ្យបានឧបសម្បទាហើយ (ការដែលឲ្យនូវឧបសម្បទាដល់សាមណេរឈ្មោះនាគនេះ ) ជាការគួរដល់ព្រះសង្ឃ ព្រោះហេតុនោះ បានជាព្រះសង្ឃស្ងៀម ខ្ញុំព្រះករុណាសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀម ដូច្នេះឯង ។

លុះចប់ញត្តិចតុត្ថកម្មវាចាស្រេច ក្នុងខណៈណា ឧបសម្បទាបេក្ខ
នោះក៏បានស្ថិតនៅក្នុងភិក្ខុភាវៈ គឺកើតជាភិក្ខុពេញបរិបូណ៌ក្នុងខណៈនោះ
តាមពុទ្ធានុញ្ញាត ។

## =ចប់វិន័យសង្ខេប=

(23) ក២៥៩.

រោងពុម្ព មិត្តភាព
កម្ពុជា-ជប៉ុន

តម្លៃ : ១៨០០៛